

# សិក្សាស្វែងយល់ពី

# សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត






ខែកញ្ញា ឆ្នាំ២០២៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**
**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកណ្តាល**

# សិក្សាស្វែងយល់ពី
# សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត



**បង្រៀនដោយគ្រូឧទ្ទេស ៖**
**ម៉េត ប៊ុនធឿន**

**រៀបរៀងដោយគរុសិស្ស: ឆន រតនា**

**ឯកទេស: ប្រវត្តិវិទ្យា-ភូមិវិទ្យា**
**មុខវិជ្ជា: ភូមិវិទ្យា**
**បង្រៀនដោយគ្រូឧទ្ទេស: ម៉េត ប៊ុនធឿន**
**ជំនាន់៣២ ឆ្នាំទី២ ឆមាសទី១**
**ឆ្នាំសិក្សា ២០២៥-២០២៦**

**ខែ សីហា ឆ្នាំ ២០២៥**

# អារម្ភកថា

ការសិក្សាស្វែងយល់ពីសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត គឺជាកិច្ចការដ៏សំខាន់មួយ ដែលបានផ្តល់នូវមេរៀនប្រវត្តិសាស្ត្រ និងការយល់ដឹងដ៏ជ្រាលជ្រៅលើវិស័យផ្សេងៗទៀត។ ប្រទេសនេះបានឆ្លងកាត់ការតស៊ូដ៏លំបាកពីអតីតកាលរហូតទទួលបានឯករាជ្យពេញលេញនៅឆ្នាំ ២០០២ ដែលនេះជាការបង្ហាញពីស្មារតីអង់អាចក្លាហាន និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់ប្រជាជនទីម័រ។

ការស្វែងយល់អំពីប្រទេសនេះមិនត្រឹមតែជាចំណេះដឹងទូទៅនោះទេ ប៉ុន្តែវាក៏ជាឱកាសដើម្បីរៀនសូត្រពីរបៀបដែលប្រទេសមួយបានកសាងខ្លួនឯងឡើងវិញពីគំនរផេះផង់នៃសង្គ្រាមប្រឆាំងការត្រួតត្រាពីឥណ្ឌូនេស៊ី។ យើងអាចវិភាគពីបញ្ហាប្រឈមនានាក្នុងការស្តារសេដ្ឋកិច្ច សង្គម និងនយោបាយឡើងវិញ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងដើម្បីធានាបាននូវសន្តិភាព និងស្ថិរភាពនយោបាយ។

លើសពីនេះទៅទៀត ការសិក្សាពីទីម័រខាងកើតក៏ជួយឱ្យយើងយល់ដឹងពីភាពចម្រុះនៃវប្បធម៌ ដែលជាការរួមបញ្ចូលគ្នារវាងប្រពៃណីក្នុងស្រុក និងឥទ្ធិពលពីសម័យអាណានិគមព័រទុយហ្គាល់។ តាមរយៈការសិក្សានេះ យើងអាចកសាងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសក្នុងតំបន់ឱ្យកាន់តែប្រសើរឡើង។

# មាតិកា

ទំព័រ


អារម្ភកថា.....I

មាតិកា.....II

១- សេចក្តីផ្តើម.....1

២- អតីតកាលដ៏ល្បីងដូរចត់.....1

៣- លក្ខខណ្ឌធម្មជាតិ.....3

៣.១- ស្ថានភាពភូមិសាស្ត្រ.....3

៣.២- សណ្ឋានដី.....4

៣.៣- អាកាសធាតុ.....5

៣.៤- ផ្លូវទឹក.....6

៣.៥- ធនធានប្រេងកាត ឧស្ម័នធម្មជាតិ និងធនធានរ៉ែ.....7

៣.៦- ព្រៃឈើ និងជីវៈចម្រុះ.....7

៤- លក្ខខណ្ឌសង្គម.....8

៤.១- ប្រព័ន្ធនយោបាយ.....8

ក- អំណាចនីតិប្រតិបត្តិ.....9

ខ- អំណាចនីតិប្បញ្ញត្តិ.....9

គ- អំណាចតុលាការ.....10

៤.២- របៀបរៀបចំផ្នែករដ្ឋបាល.....11

៤.៣- ស្ថានភាពប្រជាជន.....13

ក. លក្ខណៈទូទៅ.....13

ខ. ទម្រង់ប្រជាជន.....14

គ. សូចនាករប្រជាសាស្ត្រផ្សេងទៀត (ឆ្នាំ ២០២២).....15

៤.៤- វប្បធម៌.....15

៤.៥- សាសនា.....18

៥- ស្ថានភាពសេដ្ឋកិច្ច ........................................................ 20
៥.១- វិស័យប្រេងកាត ឧស្ម័នធម្មជាតិ និងរ៉ែ ........................................................ 21
៥.២- វិស័យកសិកម្ម ........................................................ 22
៥.៣- វិស័យឧស្សាហកម្ម ........................................................ 25
៥.៤- វិស័យទេសចរណ៍ ........................................................ 27
៥.៥- វិស័យគមនាគមន៍ ........................................................ 29
៥.៦- វិស័យពាណិជ្ជកម្ម ........................................................ 29
**ឯកសារយោង** ........................................................ i

## ១- សេចក្ដីផ្ដើម

ទីម័រខាងកើត ( Timor-Leste ) ជាប្រទេសកោះតូចមួយដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសឥណ្ឌូណេស៊ី និងភាគពាយ័ព្យនៃប្រទេសអូស្ត្រាលី។ ប្រទេសនេះមានប្រវត្តិសាស្ត្រស្មុគស្មាញ និងជាប្រវត្តិសាស្ត្រមួយដែលមានការតស៊ូដ៏យូរអង្វែងដើម្បីឯករាជ្យភាពរបស់ខ្លួន។ ការសិក្សាអំពីប្រទេសទីម័រខាងកើត មិនត្រឹមតែផ្ដោតលើប្រវត្តិសាស្ត្រនយោបាយ និងសង្គមប៉ុណ្ណោះទេ ថែមទាំងការអភិវឌ្ឍសេដ្ឋកិច្ច និងវប្បធម៌ប្រពៃណីរបស់ប្រជាជនទីម័រផងដែរ។ ប្រទេសទីម័រខាងកើត ទទួលបានឯករាជ្យពេញលេញនៅឆ្នាំ ២០០២ ក្រោយពីបានជម្នះការគ្រប់គ្រងរបស់ព័រទុយហ្គាល់ និងការកាន់កាប់របស់ឥណ្ឌូណេស៊ី។ ឯករាជ្យភាពនេះមិនមែនជារឿងងាយស្រួលឡើយ ព្រោះប្រជាជនរបស់ពួកគេបានប្រឈមមុខនឹងសង្គ្រាមស៊ីវិល និងវិបត្តិសេដ្ឋកិច្ចជាច្រើន។ ក្រោយមក ពួកគេបានងើបឈរឡើងវិញដោយពឹងផ្អែកលើធនធានធម្មជាតិសំខាន់ៗដូចជា ប្រេងកាត និងឧស្ម័នធម្មជាតិ ដែលដើរតួយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេស។

ទោះបីជាយ៉ាងណាក៏ដោយ ភាពរុងរឿងដែលបានមកពីប្រេងក៏មិនស្ថិតស្ថេរដែរ ព្រោះទិន្នផលប្រេងមានការថយចុះគួរឱ្យកត់សម្គាល់។ ដូច្នេះហើយ ប្រទេសនេះបាននិងកំពុងព្យាយាមធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការអភិវឌ្ឍវិស័យកសិកម្ម ទេសចរណ៍ និងវិស័យផ្សេងៗទៀត។ ការសិក្សាអំពីប្រធានបទនេះនឹងផ្ដល់ចំណេះដឹងយ៉ាងទូលំទូលាយអំពីរបៀបដែលប្រទេសមួយដែលមានទំហំតូច បានឆ្លងកាត់ដំណើរផ្លាស់ប្ដូរដ៏លំបាករហូតដល់ទទួលបានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ទាំងផ្នែកនយោបាយ សង្គម និងសេដ្ឋកិច្ច។

ការសិក្សាអំពីប្រទេសទីម័រខាងកើត គឺជាការសិក្សាអំពីមេរៀនមួយដ៏មានតម្លៃអំពីការតស៊ូ ភាពអត់ធ្មត់ និងមហិច្ឆតារបស់មនុស្សជាតិក្នុងការកសាងអនាគតមួយដែលប្រសើរជាងមុន។

## ២- អតីតកាលដ៏ល្វីងជូរចត់

ប្រវត្តិសាស្ត្ររបស់ទីម័រខាងកើតបានចាប់ផ្ដើមនៅដើមសតវត្សរ៍ទី១៦ នៅពេលដែលឈ្មួញជនជាតិព័រទុយហ្គាល់បានមកដល់កោះនេះ ដើម្បីធ្វើជំនួញជួញដូរធនធានធម្មជាតិដូចជា ឈើក្រអូប និងចន្ទន៍ក្រឹស្នា និងគ្រឿងទេស។ នៅពាក់កណ្ដាលសតវត្សរ៍ដដែលនោះ ពួកព័រទុយហ្គាល់បានចាប់ផ្ដើមបង្កើតអាណានិគមលើទឹកដីនេះ ហើយគ្រប់គ្រងទីម័រខាងកើតអស់រយៈពេលជិត ៤០០ ឆ្នាំ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងនេះ ទីម័រត្រូវបានបែងចែកជាពីរនៅឆ្នាំ១៨៥៩ ដោយសារការប៉ះទង្គិចគ្នាដោយអាវុធជាមួយពួកហូឡង់( ណេដឺឡែន )។ តាមកិច្ចព្រមព្រៀងឆ្នាំ១៨៥៩ កោះទីម័រត្រូវបានបែងចែកជាពីរ មួយកំណាត់កោះខាងលិចត្រួតត្រាដោយពួកហូឡង់ និងមួយកំណាត់ខាងកើតជារបស់ពួកព័រទុយហ្គាល់។ ពីឆ្នាំ១៩៤២ ដល់ឆ្នាំ១៩៤៥ ទីម័រខាងកើតត្រូវពួកជប៉ុនចូលកាន់កាប់។ ក្រោយពេលជប៉ុនចាញ់ក្នុងសង្គ្រាមលោកលើកទី២ ពួកទ័រទុយហ្គាល់ត្រឡប់មកត្រួតត្រាទីម័រខាងកើតជាថ្មីម្ដងទៀត។ ទោះបីជាមានការគ្រប់គ្រងអស់រយៈពេលយ៉ាងយូរក៏ដោយ ក៏ប្រជាជនទីម័រនៅតែបន្តប្រកាន់យកជំនឿ និងប្រពៃណីរបស់ពួកគេដដែល។ ព័រទុយហ្គាល់បានដកថយពីទីម័រនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដោយសារបញ្ហានយោបាយផ្ទៃក្នុងប្រទេស។

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ទីម័រខាងកើតបានប្រកាសឯករាជ្យចេញពីនឹមត្រួតត្រាព័រទុយហ្គាល់។ តែ ៩ ថ្ងៃក្រោយមក កងទ័ពឥណ្ឌូណេស៊ីបានចូលលុកលុយ និងកាន់កាប់ទីម័រខាងកើតនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៥ ដោយប្រកាសបញ្ចូលទឹកដីនេះជាខេត្តទី២៧ របស់ខ្លួននៅខែកក្កដា ឆ្នាំ១៩៧៦ ដោយដាក់ឈ្មោះថា ខេត្តទីម័រទីមួ(ទីម័រខាងកើត)។ ការកាន់កាប់នេះត្រូវបានអមដោយអំពើហិង្សាដ៏ឃោរឃៅដែលបណ្ដាលឱ្យមានការបាត់បង់ជីវិតប្រជាជនទីម័រខាងកើតរាប់ម៉ឺននាក់។ កងកម្លាំងតស៊ូទីម័រ (FALINTIL) ដែលដឹកនាំដោយ Kay Rala Xanana Gusmão បានបន្តប្រយុទ្ធប្រឆាំងនឹងការគ្រប់គ្រងរបស់ឥណ្ឌូណេស៊ីអស់រយៈពេលជាងពីរទសវត្សរ៍។ អស់រយៈពេលជាច្រើនឆ្នាំនៃការកាន់កាប់ របបឥណ្ឌូណេស៊ីបានប្រព្រឹត្តអំពើហិង្សា និងការសម្លាប់រង្គាលយ៉ាងសាហាវទៅលើប្រជាជនទីម័រខាងកើត ដែលធ្វើឱ្យមានការខឹងសម្បារពីក្រុមអ្នកការពារសិទ្ធិមនុស្ស និងរដ្ឋាភិបាលប្រទេសមួយចំនួន។ តាមរបាយការណ៍បានប៉ាន់ស្មានថា ក្នុងអំឡុងពេលនៃការកាន់កាប់នេះ ប្រជាជនទីម័រប្រហែល ១០០,០០០នាក់ ទៅ ២៥០,០០០ នាក់បានបាត់បង់ជីវិតដោយសារការប្រយុទ្ធគ្នា ជំងឺ និងភាពអត់ឃ្លាន។ ព្រឹត្តិការណ៍សំខាន់មួយគឺ ការសម្លាប់រង្គាលនៅទីក្រុងឌីលី(Dili) ក្នុងឆ្នាំ ១៩៩១ ដែលមានការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ធ្វើឱ្យពិភពលោកភ្ញាក់ផ្អើល និងបង្កើនសម្ពាធលើឥណ្ឌូនេស៊ី។ សហគមន៍អន្តរជាតិបានចាប់ផ្ដើមយកចិត្តទុកដាក់ខ្លាំងលើបញ្ហានេះ តែនៅក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៩០ ប៉ុណ្ណោះ។ នៅពេលដែលលោក ស៊ូហារតូ(Suharto) លាលែងពីតំណែងក្នុងឆ្នាំ ១៩៩៨ ប្រទេសឥណ្ឌូណេស៊ីបានជួបប្រទះវិបត្តិសេដ្ឋកិច្ច និងនយោបាយ។ មេដឹកនាំថ្មី លោក B.J. Habibie បានប្រឈមមុខនឹងសម្ពាធកាន់តែខ្លាំងពីប្រទេសលោកខាងលិចដូចជា សហរដ្ឋអាមេរិក អូស្ត្រាលី និងអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយបញ្ហា ទីម័រខាងកើតដោយសន្តិវិធី។ ក្រោមសម្ពាធនេះ លោក Habibie បានប្រកាសពីការផ្ដល់ជម្រើសដល់ទីម័រខាងកើតក្នុងការធ្វើប្រជាមតិ ដែលជាការផ្លាស់ប្ដូរដ៏ធំមួយ។ អង្គការសហប្រជាជាតិបានចាត់ទុកទីម័រខាងកើតជាតំបន់ដែលមិនទាន់មានអធិបតេយ្យភាព និងបន្តទទួលស្គាល់ព័រទុយហ្គាល់ជាអំណាចគ្រប់គ្រងផ្លូវការ។ ដូច្នេះ អ.ស.ប. បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរវាងឥណ្ឌូណេស៊ី និងព័រទុយហ្គាល់ ដើម្បីឈានទៅដល់ការរៀបចំប្រជាមតិនៅឆ្នាំ ១៩៩៩ ក្រោមការត្រួតពិនិត្យរបស់ខ្លួន។

នៅឆ្នាំ១៩៩៩ រដ្ឋាភិបាលឥណ្ឌូណេស៊ីបានយល់ព្រមរៀបចំការបោះឆ្នោតប្រជាមតិក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ (UN)។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ ការបោះឆ្នោតបានបង្ហាញថា ប្រជាជនទីម័រភាគច្រើនលើសលប់បានបោះឆ្នោតទាមទារឯករាជ្យពីឥណ្ឌូណេស៊ី។ ភ្លាមៗក្រោយការបោះឆ្នោត កងជីវពលប្រឆាំងឯករាជ្យដែលគាំទ្រដោយកងទ័ពឥណ្ឌូណេស៊ីបានបង្កអំពើហិង្សាយ៉ាងសាហាវ សម្លាប់ប្រជាជនទីម័រជិត ១,៤០០ នាក់ និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសស្ទើរតែទាំងស្រុង។ ជាការឆ្លើយតប នៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩៩ អង្គការសហប្រជាជាតិបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពអន្តរជាតិ(INTERFET) ដែលដឹកនាំដោយប្រទេសអូស្ត្រាលី ដើម្បីបញ្ចប់អំពើហិង្សា និងស្ដារសន្តិសុខឡើងវិញ។ ទីបំផុត នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ ទីម័រខាងកើតត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជារដ្ឋឯករាជ្យពេញលេញមួយ។



នៅចុងខែមេសា ឆ្នាំ២០០៦ ភាពតានតឹងផ្ទៃក្នុងមួយ បានគំរាមកំហែងសន្តិសុខប្រជាជាតិដ៏ក្មេងខ្ចីនេះ។ ឆ្លើយតបតាមសំណើសុំរបស់រដ្ឋាភិបាលទីម័រខាងកើត កងកម្លាំងស្ថិរកម្មអន្តរជាតិ ISF (International Stabilization Force) ដឹកនាំដោយប្រទេសអូស្ត្រាលីបានចូលមកធ្វើអន្តរាគមន៍ នៅចុងខែឧសភា ឆ្នាំ២០០៦ ។ នៅខែសីហា ឆ្នាំ២០០៦ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបញ្ជូន "ក្រុមបេសកកម្មសម្រាប់សមាហរណកម្មនៃអង្គការសហប្រជាជាតិនៅទីម័រខាងកើត " UNMIT (UN Intergrated Mission of Timor-Leste) ជំនួសឱ្យ ISF ។ ពីខែមេសាដល់ខែមិថុនា ឆ្នាំ២០០៧ រដ្ឋាភិបាលទីម័រខាងកើត បានធ្វើការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអ្នកតំណាងរាស្ត្រក្នុងបរិយាកាសប្រកបដោយសន្តិភាពក្រោមជំនួយឧបត្ថម្ភពី UNMIT និងអ្នកផ្ដល់អំណោយអន្តរជាតិ ។

## ៣- លក្ខខណ្ឌធម្មជាតិ

### ៣.១- ស្ថានភាពភូមិសាស្ត្រ




*ផែនទីនៃប្រទេសទីម័រខាងកើត*

ទីម័រខាងកើត(Timor-Leste) គឺជាប្រទេសកោះមួយនៅអាស៊ីអាគ្នេយ៍ដីកោះ ដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសអូស្ត្រាលី និងនៅចុងខាងកើតនៃប្រជុំកោះសាន់ដាតូច(Lesser Sunda Islands ឬ Nusa Tenggara) របស់ឥណ្ឌូណេស៊ី ។ប្រទេសនេះ ជាប្រទេសក្នុងទ្វីបអាស៊ីតែមួយគត់ដែលមានផ្ទៃដីស្ថិតនៅអឌ្ឍគោលខាងត្បូងនៃផែនដីទាំងស្រុង ។ ទីតាំងភូមិសាស្ត្ររបស់ប្រទេសនេះមានលក្ខណៈពិសេសដោយសារតែវាស្ថិតនៅចន្លោះ សមុទ្រទីម័រ សមុទ្រសាវូ(Savu) សមុទ្របានដា(Banda) ច្រកសមុទ្រអំបៃ(Ombai Strait) និងច្រកសមុទ្រវ៉េតា(Wetar Strait)។ ទឹកដីរបស់ទីម័រខាងកើតរួមមានពាក់កណ្ដាលខាងកើតនៃកោះទីម័រ តំបន់ដាច់ស្រយាលអូគុយស៊ី-អាំបេណូ(Oecussi-Ambeno) ដែលជាផ្នែកតូចមួយនៃភាគពាយ័ព្យនៃកោះទីម័រ ហើយត្រូវបានហ៊ុំព័ទ្ធដោយទឹកដីរបស់ឥណ្ឌូណេស៊ី ព្រមទាំងកោះអាតៅរ៉ូ(Atauro) និងកោះចាកូ(Jaco)។ កូអរដោនេភូមិសាស្ត្រនៃប្រទេសនេះគឺស្ថិតនៅចន្លោះខ្សែស្របទី ៨° និងទី ១០° នៃរយៈទទឹងខាងត្បូង និង

ចន្លោះខ្សែបណ្ដោយទី ១២៤° និងទី ១២៨° នៃរយៈបណ្ដោយខាងកើត។ ប្រទេសនេះគ្របដណ្ដប់លើផ្ទៃដីសរុប ១៥,០០៧ គីឡូម៉ែត្រការ៉េ ដែលធំជាងប្រទេសព្រុយណេ និងសិង្ហបុរី ប៉ុន្តែតូចជាងប្រទេសកម្ពុជាប្រហែល ១២ ដង។ ប្រទេសនេះមានព្រំដែនជាប់នឹងខេត្តទីម័រខាងលិចរបស់ឥណ្ឌូណេស៊ីប្រវែង ២២៨ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៧០៦ គីឡូម៉ែត្រ។

### ៣.២- សណ្ឋានដី




*ផែនទីសណ្ឋានដីនៃប្រទេសទីម័រខាងកើត*

សណ្ឋានដីរបស់ប្រទេសទីម័រខាងកើតមានលក្ខណៈសម្បូរទៅដោយភ្នំ និងខ្ពង់រាប ហើយខ្សត់ទំនាប (ទំនាបឆ្នេរតូចចង្អៀត)។ ប្រទេសនេះត្រូវបានព័ទ្ធជុំវិញដោយសមុទ្រទីម័រ សមុទ្រសាវូ(Savu) សមុទ្របានដា (Banda) ច្រកសមុទ្រអំបៃ(Ombai Strait) និងច្រកសមុទ្រវ៉េតា(Wetar Strait)។ ប្រហែល ៨០% នៃផ្ទៃដីសរុបគឺជាតំបន់ភ្នំ ដែលធ្វើឱ្យការធ្វើដំណើរ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមានការលំបាក។ ភ្នំខ្ពស់បំផុតនៅក្នុងប្រទេសគឺ ហ្វូហូ តាតាម៉ៃឡូ(Foho Tatamailau) ឬ រ៉ាមេឡៅ(Ramelau) ដែលមានកម្ពស់ ២,៩៦៣ ម៉ែត្រ ស្ថិតនៅភាគខាងត្បូងនៃរដ្ឋធានីឌីលី។

តំបន់ភ្នំទាំងនេះត្រូវបានកាត់ផ្ដាច់ដោយជ្រលងភ្នំតូចចង្អៀតជាច្រើន ដែលសម្បូរទៅដោយទន្លេ និងជ្រលងតូចៗ ដែលមានសារៈសំខាន់សម្រាប់ការផ្គត់ផ្គង់ទឹកដល់ប្រជាជន។ ម្យ៉ាងវិញទៀត តំបន់ទំនាបតូចៗនៅតាមឆ្នេរសមុទ្រមានដីមានជីជាតិសមស្របសម្រាប់វិស័យកសិកម្ម ជាពិសេសការដាំដុះដំណាំសំខាន់ៗដូចជាស្រូវ និងពោត។ តំបន់ឆ្នេរសមុទ្រមានប្រវែងសរុបប្រហែល ៧០៦ គីឡូម៉ែត្រ ដែលសម្បូរទៅដោយផ្កាថ្ម និងជីវៈចម្រុះសមុទ្រដ៏សម្បូរបែប ដែលមានសក្ដានុពលសម្រាប់វិស័យទេសចរណ៍ និងនេសាទ។

សណ្ឋានដីភ្នំនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាជនទីម័រ ដោយវាបានបង្កឱ្យមានការលំបាកក្នុងការកសាងផ្លូវថ្នល់ និងការដឹកជញ្ជូន។ យ៉ាងណាមិញ តំបន់ភ្នំទាំងនេះក៏ជាកន្លែងដាំកាហ្វេដ៏សំខាន់របស់ប្រទេស ដែលជាទំនិញនាំចេញដ៏ធំទីពីររបស់ប្រទេសនេះបន្ទាប់ពីប្រេងកាតនិងឧស្ម័នធម្មជាតិ។

យោងតាមប្រភពពី CIA World Factbook ដែលបានធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីធ្លីនៅទីម័រខាងកើតនៅឆ្នាំ២០២២ រួមមាន ដីកសិកម្ម ២៣%(ដីដាំដំណាំអចិន្ត្រៃយ៍ ៥.៤% ដីដាំដំណាំតាមរដូវ ៧.៥% ដីវាលស្មៅសម្រាប់ចិញ្ចឹមសត្វ ១០.១%) ដីព្រៃឈើ ៦១.៨% ដីផ្សេងៗទៀត ១៥.៣%។ លើសពីនេះ ដោយសារតែទីតាំងភូមិសាស្ត្ររបស់ខ្លួន ទីម័រខាងកើតងាយរងគ្រោះនឹងគ្រោះធម្មជាតិដូចជា ទឹកជំនន់ ការបាក់ដី ការរញ្ជួយដី ស៊ូណាមី និងព្យុះស៊ីក្លូនជាដើម។

### ៣.៣- អាកាសធាតុ




*ផែនទីបាយណ៍ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំនៃប្រទេសទីម័រខាងកើត*

ប្រទេសទីម័រខាងកើតមានអាកាសធាតុត្រូពិកមូសុងសមុទ្រ ដែលមានលក្ខណៈក្ដៅហើយសើម ដោយមានរដូវពីរច្បាស់លាស់គឺ រដូវវស្សា និងរដូវប្រាំង។ រដូវវស្សាមានរយៈពេលចាប់ពីខែវិច្ឆិកា ដល់ខែមេសា ដែលនាំមកនូវភ្លៀងធ្លាក់ខ្លាំង រីឯរដូវប្រាំងចាប់ពីខែឧសភា ដល់ខែតុលា គឺមានអាកាសធាតុស្ងួតហួតហែង។ សីតុណ្ហភាពជាមធ្យមនៅក្នុងប្រទេសនេះមានប្រហែល ២៦°C (ផ្អែកលើឯកសារផ្សេងទៀត សីតុណ្ហភាពមធ្យមប្រចាំឆ្នាំនៅប្រទេសទីម័រខាងកើតគឺស្ថិតនៅចន្លោះពី ២៤°C ដល់ ២៧°C) ប៉ុន្តែអាចប្រែប្រួលយ៉ាងខ្លាំងទៅតាមកម្ពស់ភូមិសាស្ត្រ។ តំបន់ឆ្នេរមានអាកាសធាតុក្ដៅ ដូចជារដ្ឋធានីឌីលី ដោយមានកម្ដៅចន្លោះពី ២៥°C ទៅ ៣៥°C។ រី

ឯតំបន់ភ្នំមានសីតុណ្ហភាពត្រជាក់ជាង ហើយសីតុណ្ហភាពជាមធ្យមអាចធ្លាក់ចុះដល់ ១៤°C ទៅ ២១°C អាស្រ័យលើកម្ពស់។ អាកាសធាតុរបស់ប្រទេសនេះក៏រងឥទ្ធិពលយ៉ាងខ្លាំងពីបាតុភូតធម្មជាតិដូចជា ខ្យល់មូសុង និងបាតុភូតអែលនីញ៉ូ( El Niño ) និងឡានីណា( La Niña ) ដែលអាចបណ្ដាលឱ្យមានការប្រែប្រួលបរិមាណទឹកភ្លៀងប្រចាំឆ្នាំរហូតដល់ ៥០%។ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំខ្ពស់ជាង ១០០០ mm ។ មូសុងវស្សាបក់មកពីទិសពាយ័ព្យ និងមូសុងប្រាំងបក់មកពីទិសអាគ្នេយ៍។ ជាអកុសល ប្រទេសទីម័រខាងកើតងាយរងគ្រោះខ្លាំងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមមានសីតុណ្ហភាពកើនឡើង គ្រោះរាំងស្ងួត ទឹកជំនន់ និងព្យុះស៊ីក្លូន ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យកសិកម្ម និងបណ្ដាញគមនាគមន៍ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ។

### ៣.៤- ផ្លូវទឹក




*ផែនទីបណ្ដាញផ្លូវទឹកនៃប្រទេសទីម័រខាងកើត*

ប្រព័ន្ធផ្លូវទឹកនៅប្រទេសទីម័រខាងកើតភាគច្រើនជាទន្លេខ្លីៗ ដែលមានលំហូរយ៉ាងលឿន ដោយសារតែវាហូរចុះពីតំបន់ភ្នំខ្ពស់ៗកាត់ទំនាបឆ្នេរដ៏តូចចង្អៀត រួចចាក់ទៅក្នុងសមុទ្រ។ ទន្លេទាំងនេះ ភាគច្រើនរីងស្ងួត ឬមានទឹកតិចតួចណាស់ក្នុងរដូវប្រាំង( ពីខែឧសភាដល់ខែតុលា ) ប៉ុន្តែមានលំហូរខ្លាំង និងអាចបង្កជាជំនន់បានក្នុងរដូវវស្សា( ពីខែវិច្ឆិកា ដល់ខែមេសា )។ ទោះបីជាយ៉ាងនេះក្តី ផ្លូវទឹកទាំងនេះដើរតួនាទីយ៉ាងសំខាន់សម្រាប់ការផ្គត់ផ្គង់ទឹកសាប ក៏ដូចជាសម្រាប់ប្រព័ន្ធធារាសាស្ត្រលើផ្ទៃដីប្រមាណ ១ ០៦៥ គីឡូម៉ែត្រការ៉េ។ ជាទូទៅ ផ្លូវទឹកទាំងនេះមិនអាចប្រើប្រាស់សម្រាប់ធ្វើនាវាចរណ៍សម្រាប់នាវាធំបានឡើយៗ។ ទោះបីជាមិនអាចធ្វើនាវាចរណ៍បានក៏ដោយ ក៏ទន្លេទាំងនេះដើរតួនាទីយ៉ាងសំខាន់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ ទន្លេឡាក្លូ

(Laclo) ជាទន្លេដ៏សំខាន់មួយដែលហូរចូលទៅក្នុងទីក្រុងឌីលីក្នុងរដូវវស្សា។ ទន្លេឡូស(Loes) មានទីតាំងនៅភាគពាយ័ព្យនៃប្រទេស ហើយត្រូវបានគេចាត់ទុកថាជាប្រព័ន្ធទន្លេធំជាងគេបំផុត។ ទន្លេកូម៉ូរ៉ូ(Comoro) មានទីតាំងនៅជិតរដ្ឋធានីឌីលី។ ផ្លូវទឹកនេះត្រូវបានប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹក។

### ៣.៥- ធនធានប្រេងកាត ឧស្ម័នធម្មជាតិ និងធនធានរ៉ែ

ប្រទេសទីម័រខាងកើតមានធនធានប្រេងកាត និងឧស្ម័នធម្មជាតិដ៏សម្បូរបែប ដែលមានទីតាំងនៅបាតសមុទ្រទីម័រ(Timor Sea) ហើយធនធានទាំងនេះបានក្លាយជាប្រភពចំណូលដ៏សំខាន់បំផុតរបស់ប្រទេស ចាប់តាំងពីទទួលបានឯករាជ្យមក។ យោងតាមរបាយការណ៍ដែលបានប្រមូលផ្ដុំពីស្ថាប័នដូចជា EITI និងធនាគារពិភពលោក ចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ វិស័យប្រេងកាតនិងឧស្ម័នធម្មជាតិបានរួមចំណែកប្រមាណ ១៦% នៃផលិតផលក្នុងស្រុកសរុប(GDP) និងបានផ្ដល់ចំណូលដល់រដ្ឋចន្លោះពី ៦៥% ទៅ ៨០% នៃចំណូលរដ្ឋប្រចាំឆ្នាំ។ ជាក់ស្ដែង ក្នុងឆ្នាំ២០២០ វិស័យនេះនៅតែជាប្រភពចំណូលដ៏សំខាន់សម្រាប់រដ្ឋាភិបាល ដោយទទួលបានចំណូលជាង ៦៥%។ ទោះជាយ៉ាងនេះក្ដី ទិន្នន័យថ្មីៗបានបង្ហាញថា ចាប់ពីឆ្នាំ២០២០ មកជាពិសេសនៅឆ្នាំ ២០២៣ ចំណូលពីវិស័យប្រេងកាតនិងឧស្ម័នធម្មជាតិបានធ្លាក់ចុះយ៉ាងខ្លាំង ហើយការរួមចំណែករបស់វាទៅក្នុង GDP ក៏បានថយចុះគួរឱ្យកត់សម្គាល់ផងដែរ។ ទោះបីជាមានការធ្លាក់ចុះនេះក៏ដោយ វិស័យប្រេងនៅតែរក្សាបាននូវសារៈសំខាន់ចំពោះចំណូលរដ្ឋរបស់ប្រទេស។

បរិមាណប្រេងកាត និងឧស្ម័ននៅប្រទេសទីម័រខាងកើតត្រូវបានគេប៉ាន់ប្រមាណដោយផ្អែកលើតំបន់អភិវឌ្ឍន៍ធំៗចំនួនពីរ។ ទីមួយ គម្រោងបាយូអ៊ុនដាន(Bayu-Undan) ដែលជាប្រភពចំណូលចម្បងរបស់ប្រទេស មានទុនបម្រុងដើមប្រហែល ៤០០ លានបារ៉ែលនៃប្រេងកាត និង ៣,៤ ពាន់ពាន់លានហ្វីតគូបនៃឧស្ម័នធម្មជាតិ។ ទុនបម្រុងប្រេងទាំងនេះត្រូវគេបានទាញយករីងស្ងួតអស់ហើយ ដែលការផលិតបានបញ្ឈប់ទាំងស្រុងនៅឆ្នាំ២០២៥។ ទីពីរ គម្រោងហ្គ្រេតធ័រសាន់រ៉ាយ(Greater Sunrise) ដែលជាក្ដីសង្ឃឹមសម្រាប់អនាគតសេដ្ឋកិច្ច មានទុនបម្រុងដ៏ច្រើនសម្បូរបែប ដោយត្រូវបានគេប៉ាន់ស្មានថាមានឧស្ម័នប្រមាណ ៥,១៣ ពាន់ពាន់លានហ្វីតគូប និង Condensateប្រហែល ២២៦ លានបារ៉ែល។ ក្រៅពីប្រេងកាត និងឧស្ម័នធម្មជាតិ ប្រទេសទីម័រខាងកើតក៏មានសក្ដានុពលលើធនធានរ៉ែផងដែរ។ ការសិក្សាស្រាវជ្រាវបឋមបានបង្ហាញពីវត្តមានរបស់រ៉ែមួយចំនួន ដែក មាស ប្រាក់ សំណប៉ាហាំង ម៉ង់ហ្គាណែស ថ្មម៉ាប ក្រូមីត និងលោហៈធាតុផ្សេងៗ និងមានខ្សាច់ ថ្មបាយក្រៀម ហាលីត យ៉ូរ៉ានីញ៉ូម និងថ្មសំណង់ជាមដើម។ ទោះជាយ៉ាងណាក៏ដោយ ធនធានរ៉ែទាំងនេះនៅមិនទាន់ត្រូវបានអភិវឌ្ឍនៅឡើយទេ ដោយសារកង្វះខាតហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ការវិនិយោគ និងការរុករកលម្អិត។ ការអភិវឌ្ឍវិស័យរ៉ែអាចជួយដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងកាត់បន្ថយការពឹងផ្អែករបស់ប្រទេសលើវិស័យប្រេងកាត និងឧស្ម័ននាពេលអនាគត។

### ៣.៦- ព្រៃឈើ និងជីវៈចម្រុះ

ប្រទេសទីម័រខាងកើតដែលស្ថិតនៅចន្លោះទ្វីបអាស៊ី និងទ្វីបអូស្ត្រាលី គឺជាទីតាំងភូមិសាស្ត្រដ៏ពិសេសមួយ ដែលធ្វើឱ្យវាមានប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះដ៏សម្បូរបែប។ ដែនដីដ៏តូចមួយនេះមានទាំងព្រៃឈើដ៏

ចម្រុះ ជីវិតសត្វប្លែកៗ និងរុក្ខជាតិដ៏កម្រៗ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវិតប្រចាំថ្ងៃរបស់ប្រជាជន និងរក្សាតុល្យភាពបរិស្ថាន។

ព្រៃឈើនៅទីម័រខាងកើតមានលក្ខណៈខុសៗគ្នាទៅតាមកម្ពស់ និងអាកាសធាតុ។ នៅតំបន់ដីទំនាបដែលមានអាកាសធាតុស្ងួត គេអាចរកឃើញ ព្រៃត្រូពិកជ្រុះស្លឹក ដែលដើមឈើភាគច្រើនបាត់បង់ស្លឹករបស់ខ្លួនក្នុងរដូវប្រាំង។ ផ្ទុយទៅវិញ នៅតំបន់ខ្ពង់រាប និងជួរភ្នំដែលមានសំណើមខ្ពស់ គឺជាប្រភេទព្រៃស្រោងត្រូពិកដែលតែងតែមានពណ៌បៃតងពេញមួយឆ្នាំ។ ក្រៅពីនេះ តាមបណ្ដោយឆ្នេរនៃប្រទេស ក៏មានព្រៃកោងកាង ដែលដើរតួជាកន្លែងការពារឆ្នេរពីសំណឹកដី និងជាជម្រកដ៏សំខាន់សម្រាប់ជីវិតសត្វសមុទ្រ។ ទោះបីជាសម្បូរដោយព្រៃឈើក៏ដោយ ក៏ធនធានទាំងនេះកំពុងរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរពីការកាប់បំផ្លាញព្រៃឈើដើម្បីពង្រីកផ្ទៃដីកសិកម្ម ការកាប់ឈើខុសច្បាប់ និងការទាញយកឈើសម្រាប់ធ្វើជាអុស ដែលជាបញ្ហាប្រឈមធំមួយសម្រាប់និរន្តរភាពបរិស្ថានរបស់ប្រទេស( FAO, 2020 )។

ជីវៈចម្រុះនៅទីម័រខាងកើតបង្ហាញពីការលាយបញ្ចូលគ្នារវាងប្រភេទសត្វនិងរុក្ខជាតិរបស់អាស៊ី និងអូស្ត្រាលី។ ប្រទេសនេះជាជម្រកសម្រាប់សត្វជាច្រើនប្រភេទ រួមទាំងប្រភេទសត្វកម្រ និងរស់នៅតែក្នុងតំបន់នេះផងដែរ។ បក្សីប្រមាណ ២៥៣ ប្រភេទត្រូវបានគេរកឃើញនៅទីនោះ ក្នុងនោះមានបក្សីចំនួន ៥ ប្រភេទជាប្រភេទសត្វដែលរស់នៅតែក្នុងតំបន់នេះប៉ុណ្ណោះ ដូចជា សត្វព្រាបបៃតងទីម័រ( Timor Green Pigeon ) និងសត្វចាបទីម័រ ( Timor Sparrow )។ ក្រៅពីនេះ គេក៏អាចរកឃើញសត្វល្មូនជាច្រើនប្រភេទដូចជា ក្រពើទឹកប្រៃ ឬក្រពើភ្លើង( Crocodylus porosus ) និងសត្វពស់ផ្សេងៗទៀត។ ព្រៃឈើរបស់ទីម័រជាជម្រកសម្រាប់រុក្ខជាតិរាប់រយប្រភេទ រួមទាំងប្រភេទរុក្ខជាតិសំខាន់ៗដូចជា ដើមខ្លឹមចន្ទន៍ក្រឹស្នា ដែលជាប្រភេទឈើមានតម្លៃខ្ពស់ ប៉ុន្តែក៏ជាប្រភេទដែលរងការកាប់បំផ្លាញយ៉ាងខ្លាំងផងដែរ។ លើសពីនេះ ព្រៃភ្នំក៏មានប្រភេទរុក្ខជាតិត្រូពិកជាច្រើនទៀតដូចជា ដើមឫស្សី ដើមកាហ្វេ និងដើមដូងជាដើម។

## ៤- លក្ខខណ្ឌសង្គម

### ៤.១- ប្រព័ន្ធនយោបាយ

ប្រទេសទីម័រខាងកើតមាននាមជាផ្លូវការថា «សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត» និងមានរដ្ឋធានីឈ្មោះ ទីក្រុងឌីលី( Dili )។ ប្រទេសទីម័រខាងកើតប្រារព្ធថ្ងៃបុណ្យឯករាជ្យរបស់ខ្លួននៅថ្ងៃទី២០ ខែឧសភា។ កាលបរិច្ឆេទនេះត្រូវបានកំណត់ឡើងដើម្បីរំលឹកដល់ថ្ងៃដែលអង្គការសហប្រជាជាតិបានប្រគល់អំណាចគ្រប់គ្រងទៅឱ្យរដ្ឋាភិបាលទីម័រខាងកើតវិញនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ បន្ទាប់ពីរយៈពេល ២៤ ឆ្នាំនៃការគ្រប់គ្រងដោយឥណ្ឌូនេស៊ី។ នេះជាការបញ្ចប់ដំណើរផ្លូវដ៏វែងឆ្ងាយ និងលំបាកដើម្បីទទួលបានឯករាជ្យភាពពេញលេញ។

ប្រព័ន្ធនយោបាយរបស់ប្រទេសទីម័រខាងកើតគឺជា សាធារណរដ្ឋប្រជាធិបតេយ្យបែបពាក់កណ្ដាលប្រធានាធិបតីនិយម។ របបគ្រប់គ្រងផ្នែកនយោបាយបានបែងចែកអំណាចជាបីផ្នែកដាច់ដោយឡែកពីគ្នាគឺ អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ ដែលមានតុល្យភាពអំណាចរវាងគ្នាទៅវិញទៅ

មក។ ប្រព័ន្ធនេះមានលក្ខណៈស្រដៀងទៅនឹងប្រព័ន្ធនយោបាយរបស់ប្រទេសព័រទុយហ្គាល់ ដែលជាអតីតអាណានិគមរបស់ខ្លួន។

### ក- អំណាចនីតិប្រតិបត្តិ

អំណាចនេះមានតួនាទីក្នុងការអនុវត្តច្បាប់ និងគ្រប់គ្រងប្រទេស រួមមានប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល។ ប្រមុខរដ្ឋ គឺជាប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ដែលតំណាងឱ្យប្រទេសជាតិទាំងមូល ហើយត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋដោយសំឡេងដាច់ខាតតាមរយៈប្រព័ន្ធបោះឆ្នោតពីរជុំ សម្រាប់អាណត្តិ ៥ ឆ្នាំ។ ប្រធានាធិបតីធានានូវការគោរពរដ្ឋធម្មនុញ្ញ និងស្ថាប័នរដ្ឋ ហើយនៅពេលចាំបាច់អាចដើរតួជាអ្នកសម្របសម្រួលដោះស្រាយជម្លោះនយោបាយ។ ទោះបីជាអំណាចប្រធានាធិបតីមានកម្រិតក៏ដោយ ក៏ប្រធានាធិបតីមានអំណាចឬតួនាទីដ៏សំខាន់មួយចំនួនដូចជាៈ

- អំណាចវេតូច្បាប់ (veto): ប្រធានាធិបតីអាចបដិសេធមិនចុះហត្ថលេខាលើច្បាប់ដែលដាក់ចេញដោយរដ្ឋាភិបាល និងអនុម័តដោយសភាជាតិបានដែរ។
- អំណាចរំលាយសភាៈ ក្នុងករណីមានវិបត្តិនយោបាយធ្ងន់ធ្ងរ ប្រធានាធិបតីអាចរំលាយសភាជាតិ ហើយការបោះឆ្នោតថ្មីត្រូវតែធ្វើឡើងយ៉ាងយូរមិនលើសពី ៩០ ថ្ងៃ បន្ទាប់ពីការរំលាយនោះ។
- តែងតាំងនាយករដ្ឋមន្ត្រីៈ តែងតាំងនាយករដ្ឋមន្ត្រីពីមេដឹកនាំគណបក្សនយោបាយដែលមានសំឡេងភាគច្រើនដាច់ខាតនៅក្នុងសភាជាតិ ឬក្រុមសម្ព័ន្ធភាពដែលមានសំឡេងភាគច្រើនក្នុងសភាជាតិ។
- ក្នុងនាមជាប្រមុខរដ្ឋ ប្រធានាធិបតីក៏ជាប្រធានក្រុមប្រឹក្សារដ្ឋ ប្រធានក្រុមប្រឹក្សាកំពូលផ្នែកការពារជាតិ និងសន្តិសុខផងដែរ
- មានអំណាចតែងតាំងប្រធានតុលាការឧទ្ធរណ៍ផងដែរ បន្ទាប់ពីពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល។

នាយករដ្ឋមន្ត្រី គឺជាប្រមុខរដ្ឋាភិបាល និងជាអ្នកដឹកនាំជាក់ស្តែងរបស់ប្រទេស។ រដ្ឋាភិបាល គឺជាស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋ ហើយទទួលខុសត្រូវក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល។ នាយករដ្ឋមន្ត្រីទីម័រខាងកើតកើតឡើងតាមរយៈការតែងតាំងដោយប្រធានាធិបតី ប៉ុន្តែត្រូវឆ្លងកាត់ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីសភាជាតិជាមុនសិន ដែលមានអាណត្តិ ៥ ឆ្នាំ។ នាយករដ្ឋមន្ត្រីដឹកនាំ គណៈរដ្ឋមន្ត្រី និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់រដ្ឋាភិបាល។ នាយករដ្ឋមន្ត្រីទទួលខុសត្រូវចំពោះសភាជាតិ ហើយត្រូវលាលែងពីតំណែងប្រសិនបើសភាជាតិបោះឆ្នោតដកសេចក្តីទុកចិត្ត។

### ខ- អំណាចនីតិប្បញ្ញត្តិ

ប្រទេសទីម័រខាងកើតមានប្រព័ន្ធឯកសភា គឺមាន **សភាជាតិ** (National Parliament) តែមួយគត់ដែលសមាជិកទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសពីប្រជាពលរដ្ឋតាមរយៈប្រព័ន្ធសមាមាត្របញ្ជីតំណាងគណបក្សបិទ សម្រាប់អាណត្តិ ៥ ឆ្នាំ។ ចំនួនអាសនៈអាចប្រែប្រួលពីអប្បបរមា ៥២ ទៅអតិបរមា ៦៥ អាសនៈ។ គណបក្សនយោបាយស្របច្បាប់ទាំងអស់អាចចូលរួមការបោះឆ្នោតជ្រើសរើសសមាជិកសភាជាតិ ដោយរៀបចំបញ្ជីបេក្ខជនរបស់ខ្លួនទៅកាន់សភាជាតិ។ សភាជាតិមានតួនាទីស្នូលសំខាន់ៗគឺ

- បង្កើត និងអនុម័តច្បាប់: សភាជាតិមានភារកិច្ចរៀបចំ និងអនុម័តច្បាប់នានាដើម្បីបម្រើផលប្រយោជន៍ជាតិ និងប្រជាជន។
- ត្រួតពិនិត្យអំណាចនីតិប្រតិបត្តិ: សភាជាតិដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យរដ្ឋាភិបាល (អំណាចនីតិប្រតិបត្តិ) ដើម្បីធានាថាការអនុវត្តគោលនយោបាយ និងការប្រើប្រាស់ថវិកាមានតម្លាភាព និងប្រសិទ្ធភាព។
- ផ្តល់តុល្យភាពអំណាច: តាមរយៈការអនុម័ត ឬបដិសេធច្បាប់ សភាជាតិជួយផ្តល់តុល្យភាពដល់អំណាចរបស់ប្រធានាធិបតី និងរដ្ឋាភិបាល។

កាលពីសម័យបោះឆ្នោតចុងក្រោយបង្អស់ដែលបានធ្វើឡើងនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២៣ គណបក្សនយោបាយនានាបានទទួលលទ្ធផលដូចជាគណបក្ស CNRT ទទួលបាន ៣១ អាសនៈ គណបក្ស FRETILIN ទទួលបាន ១៩ អាសនៈ គណបក្ស PD ទទួលបាន ៦ អាសនៈ គណបក្ស KHUNTO ទទួលបាន ៥ អាសនៈ គណបក្ស PLP ទទួលបាន ៤ អាសនៈ។ លទ្ធផលនេះបានអនុញ្ញាតឱ្យគណបក្ស CNRT ដែលដឹកនាំដោយលោក Xanana Gusmão អាចបង្កើតរដ្ឋាភិបាលចម្រុះថ្មីបានរវាងគណបក្ស CNRT និងគណបក្សប្រជាធិបតេយ្យ(PD)។ លើសពីនេះ អត្រាអ្នកចូលរួមបោះឆ្នោតមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ ពោលគឺរហូតដល់ ៧៩.៣% នៃអ្នកចុះឈ្មោះសរុប។ គួរកត់សម្គាល់ផងដែរថា លោកស្រី Maria Fernanda Lay ដែលមកពីគណបក្ស CNRT ត្រូវបានជ្រើសតាំងជាប្រធានសភាជាតិថ្មី ដែលធ្វើឱ្យលោកស្រីក្លាយជាស្ត្រីដំបូងគេក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសទីម័រខាងកើតដែលកាន់តំណែងនេះ។ សមាសភាពសភាទាំងមូលមានសរុប ៦៥នាក់ ដែលមានបុរស ៤៣ នាក់ និងស្ត្រី ២២ នាក់។

**គ- អំណាចតុលាការ**

តុលាការត្រូវបានគេចាត់ទុកថាជាស្ថាប័នឯករាជ្យ ព្រោះមានអំណាចពេញលេញក្នុងការគ្រប់គ្រងយុត្តិធម៌ក្នុងនាមប្រជាជន។ តួនាទីនេះមានសារៈសំខាន់ខ្លាំងក្នុងការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងធានាថាច្បាប់ទាំងអស់ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវនិងស្មើភាពគ្នា។ តុលាការមិនត្រឹមតែដោះស្រាយវិវាទប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នករក្សាតុល្យភាពអំណាចរវាងអំណាចនីតិប្រតិបត្តិ និងអំណាចនីតិប្បញ្ញត្តិ(សភាជាតិ) ផងដែរ ដើម្បីធានានូវសង្គមប្រជាធិបតេយ្យមួយដែលមាននីតិរដ្ឋពិតប្រាកដ។ ប្រព័ន្ធតុលាការ ត្រូវបានបង្កើតឡើងដោយមានឯករាជ្យភាពពីអំណាចនីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិ។

តុលាការកំពូលនៃយុត្តិធម៌ គឺជាស្ថាប័នតុលាការខ្ពស់បំផុត និងមានអំណាចក្នុងការបកស្រាយច្បាប់ជាចុងក្រោយ។ គោលបំណងនាពេលអនាគតរបស់តុលាការនេះ គឺធានាឱ្យមានឯកភាពច្បាប់ និងធ្វើការសម្រេចចិត្តចុងក្រោយលើរឿងក្តីសំខាន់ៗ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ន តុលាការកំពូលនៃយុត្តិធម៌របស់ទីម័រខាងកើតមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ដោយមានចែងតែនៅក្នុងរដ្ឋធម្មនុញ្ញ។ ដូច្នេះអំណាច និងភារកិច្ចរបស់តុលាការនេះ ត្រូវបានអនុវត្តដោយ តុលាការឧទ្ធរណ៍ ជាបណ្តោះអាសន្ន។ យោងតាមច្បាប់ចៅក្រមត្រូវតែមានបទពិសោធន៍យ៉ាងតិច ២០ ឆ្នាំទើបអាចត្រូវបានតែងតាំងជាប្រធានតុលាការនេះ។ តុលាការឧទ្ធរណ៍ មានតួនាទីពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ស្រុក។ តុលាការនេះផ្តោតសំខាន់លើការអនុវត្តច្បាប់ និងនីតិវិធី មិនមែនលើអង្គហេតុទេ។ បច្ចុប្បន្ន តុលាការឧទ្ធរណ៍ក៏ដើរតួជាតុលាការកំពូលនៃ

យុត្តិធម៌បណ្ដោះអាសន្នផងដែរ ដោយសារតុលាការកំពូលនៃយុត្តិធម៌ពិតប្រាកដមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ។ បច្ចុប្បន្ន ប្រធានតុលាការឧទ្ធរណ៍ត្រូវបានតែងតាំងដោយប្រធានាធិបតី បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល។ ថ្មីៗនេះ លោកអាហ្វុនសូ ការម៉ូណា( Afonso Carmona ) ដែលមានបទពិសោធន៍ជាង ២៥ ឆ្នាំជាចៅក្រម ត្រូវបានតែងតាំងជាប្រធានតុលាការឧទ្ធរណ៍ថ្មី។ តុលាការថ្នាក់ស្រុក ដើរតួជាតុលាការដំបូងគេបង្អស់ ដែលទទួលបន្ទុកដោះស្រាយរឿងក្ដីថ្នាក់ដំបូង ទាំងផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ ពួកគេមានមុខងារប្រមូលភស្តុតាង និងធ្វើសេចក្ដីសម្រេចលើរឿងក្ដី។

## ៤.២- រៀបរៀបចំផ្នែករដ្ឋបាល




*ការបែងចែករដ្ឋបាលគ្រប់គ្រងស្រុក(Municipality )ទាំង១៤ នៃប្រទេសទីម័រខាងកើត*

ទីម័រខាងកើតមានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងដោយចែកចេញជាស្រុក( Municipality ) ប៉ុស្តិ៍រដ្ឋបាល ( Administrative Post ) ឃុំ( Sucos ) និងភូមិ( Aldeia )។ ដោយចែកចេញជា ១៤ ស្រុក( Municipality ) ( គិតត្រឹមឆ្នាំ២០២៤ ) ស្រុកទាំងនោះរួមមាន ស្រុកបូបូណារ៉ូ( Bobonaro ), ស្រុកលីគីកា( Liquiçá ), ស្រុកឌីលី ( Díli ), ស្រុកបៅកៅ( Baucau ), ស្រុកម៉ាណាតួតូ( Manatuto ), និងស្រុកឡៅតេម( Lautém ) នៅឆ្នេរភាគខាងជើង និងស្រុកអាតៅរ៉ូ( Atauro ) ជាស្រុកកោះភាគខាងជើងរដ្ឋធានីឌីលី។ ស្រុកកាវ៉ា-លីម៉ា( Cova-Lima ), ស្រុកអៃណារ៉ូ( Ainaro ), ស្រុកម៉ានូហ្វាហ៊ី( Manufahi ), និងស្រុកវីកេកេ( Viqueque ) នៅឆ្នេរភាគខាងត្បូង។ ស្រុកអេមេរ៉ា( Ermera ) និងស្រុកអៃឡេវ( Aileu ) ជាស្រុកដែលមិនមានព្រំប្រទល់ជាប់សមុទ្រ។ និងស្រុកអូគុយស៊ី-អាំបេណូ( Oecussi-Ambeno ) ជាដែនដីផ្ដាច់ចេញដែលព័ទ្ធជុំវិញដោយទឹកដីឥណ្ឌូណេស៊ី។ ព្រំដែនកំណត់ស្រុកទាំង ១៤ នេះនៅតែដូចដើមតាំងពីសម័យរដ្ឋបាលរបស់ព័រទុយហ្គាល់មកម្ល៉េះ។ ស្រុកនីមួយៗមានទីរួមស្រុកមួយ និងមានប៉ុស្តិ៍រដ្ឋបាល( Administrative Post ) ជាច្រើន ដែលចំនួនអាចប្រែប្រួលពីបីទៅប្រាំពីរ

ជាមួយនឹងចំនួនជាមធ្យមប្រាំប៉ុស្ត៍រដ្ឋបាលក្នុងមួយស្រុក។ តាមស្ថិតិប្រជាសាស្ត្រ ស្រុកឌីលីមានប្រជាជនប្រមូលផ្តុំច្រើនជាងគេ ខណៈដែលស្រុកAileu មានអត្រាប្រជាជនទាបបំផុត ទោះបីជាផ្ទៃដីរបស់វាធំជាងឌីលីក៏ដោយ។




***ផែនទីប៉ុស្ត៍រដ្ឋបាលនៃប្រទេសទីម័រខាងកើតនៅឆ្នាំ២០១៥***

ស្រុកទាំង ១៤ ត្រូវបានបែងចែកទៅជា ៧០ ប៉ុស្ត៍រដ្ឋបាល(គិតត្រឹមឆ្នាំ២០២៤)ដោយមានប៉ុស្ត៍រដ្ឋបាលមួយត្រូវបានកំណត់ជាទីរួមស្រុក។ ប៉ុស្ត៍រដ្ឋបាលនីមួយៗត្រូវបានបែងចែកជាបន្តទៀតទៅជាឃុំ(Sucos) ដែលមានចំនួនប្រែប្រួលពី ២ ទៅ ១៨ ក្នុងមួយប៉ុស្ត៍រដ្ឋបាល។ ការបែងចែករដ្ឋបាលនៅទីម័រខាងកើត បន្ទាប់ពីប៉ុស្ត៍រដ្ឋបាលគឺ ឃុំ(Sucos)ឬ "suku" ដែលអាចរួមបញ្ចូលភូមិតូចៗជាច្រើន។ ការបែងចែករដ្ឋបាលតូចបំផុតនៅទីម័រខាងកើតគឺ ភូមិ(Aldeia) ដែលចំណុះឱ្យការគ្រប់គ្រងរបស់ឃុំ។

ស្រុកឌីលីស្ថិតនៅឆ្នេរភាគខាងជើងនៃកោះទីម័រខាងកើត។ វាមានព្រំប្រទល់ជាប់ស្រុកម៉ាណាតួតូ (Manatuto) នៅភាគខាងកើត, ស្រុកអៃឡេវ(Aileu) នៅភាគខាងត្បូង, ស្រុកលីគីកា(Liquiçá) នៅភាគខាងលិច និងសមុទ្រសាវូ (Savu Sea) នៅភាគខាងជើង។ យោងតាមទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០២២ ស្រុកឌីលីមានប្រជាជនសរុប ៣២៤,៧៣១ នាក់ និងមានផ្ទៃដីត្រឹមតែ ៣៦៨.១២ គីឡូម៉ែត្រការ៉េ (មានការផ្លាស់ប្តូរផ្ទៃដីដោយសារការបំបែកស្រុកថ្មី)។ វាគឺជាស្រុកដែលមានទំហំតូចជាងគេបំផុតក្នុងប្រទេស ប៉ុន្តែមានប្រជាជនច្រើនជាងគេបំផុត។ ទីរួមស្រុករបស់វាគឺទីក្រុងឌីលី ដែលជារដ្ឋធានីរបស់ជាតិ។ បច្ចុប្បន្ននេះ ស្រុកឌីលីត្រូវបានបែងចែកទៅជាប៉ុស្ត៍រដ្ឋបាល(Administrative Post) ចំនួន ៥ ដោយសារតែកោះ Atauro ដែលពីមុនជាប៉ុស្ត៍រដ្ឋ

បាលមួយត្រូវបានដំឡើងឋានៈជាស្រុកពេញលេញនៅដើមឆ្នាំ ២០២២។ ប៉ុស្តិ៍រដ្ឋបាលទាំង ៥ ដែលនៅសល់រួមមាន Cristo-Rei, Dom Aleixo, Nain Feto, Metinaro និង Vera Cruz ។







*ក្រាបបង្ហាញពីការបែងចែកផ្ទៃដីតាមស្រុក និងប្រជាជនគិតជាភាគរយ(២០២២)*

## ៤.៣- ស្ថានភាពប្រជាជន

### ក. លក្ខណៈទូទៅ

ទីម័រខាងកើតមានប្រជាជនសរុប ១,៣៤១,៧៣៧ នាក់ (ជំរឿនឆ្នាំ ២០២២)។ គិតជាដង់ស៊ីតេមធ្យមមានប្រមាណ ៩០ នាក់/គីឡូម៉ែត្រការ៉េ។ ដែលមានប្រជាជនភេទប្រុសសរុបប្រមាណ ៦៨១ ពាន់នាក់ និងមានប្រជាជនភេទស្រីសរុបប្រមាណ ៦៦០ ពាន់នាក់។ យោងតាមទិន្នន័យពីស្ថាប័នធនាគារពិភពលោក (World Bank) តម្លៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ(GDP per capita) របស់ទីម័រខាងកើតសម្រាប់ឆ្នាំ ២០២៤ មានចំនួន ១,៣៤៣.១៥ ដុល្លារអាមេរិក។ ចំពោះក្រុមជនជាតិវិញ គេឃើញមានក្រុមជនជាតិអំបូរអូស្ត្រូនេស៊ី(Austronesian) និងអំបូរប៉ាពួអាន(Papuan) និងអន្តោប្រវេសន៍ចិនតិចតួច។ ផ្នែកជំនឿសាសនាវិញមាន រ៉ូម៉ាំងកាតូលិក(៩៧.៥%) ប្រូតេស្តង់ និងគ្រិស្តសាសនាផ្សេងទៀត(១.៩%) ឥស្លាមសាសនា (០.៣%)និងសាសនាផ្សេងទៀត (០,៣%)។។ ភាសាផ្លូវការ គឺភាសាតេទុម (Tetum) និងភាសាព័រទុយ

ហ្គាល់។ ក្រៅពីនេះមានភាសាឥណ្ឌូណេស៊ី ភាសាអង់គ្លេស និងគ្រាមភាសាចំនួនប្រហែល ១៦ ទៀត។ ភាសាតេទុម( Tetum ) ភាសាម៉ាំបាអៀ ( Mambae ) ភាសាខេម៉ាក( Kemak ) និងភាសាប៊ូណាក់( Bunak ) ត្រូវបាននិយាយដោយប្រជាជនក្នុងចំនួនច្រើនគួរឱ្យកត់សម្គាល់។




*ប្រជាជនទីម័រខាងកើត*

**ខ. ទម្រង់ប្រជាជន**

ផ្អែកលើទិន្នន័យពីជំរឿនប្រជាជនទីម័រខាងកើតឆ្នាំ ២០២២ ដែលជាទិន្នន័យចុងក្រោយបំផុត គេអាចបែងចែកទម្រង់ប្រជាជនបានដូចខាងក្រោម៖

- ក្រុមវ័យកុមារ( 0-១៤ ឆ្នាំ ): មាន ៣៥% នៃប្រជាជនសរុប ស្មើនឹងប្រមាណ ៤៦៩.៦ ពាន់នាក់។
- ក្រុមវ័យពលកម្ម( ១៥-៦៤ ឆ្នាំ ): មាន ៥៩% នៃប្រជាជនសរុប ស្មើនឹងប្រមាណ ៧៩១.៦ ពាន់នាក់។
- ក្រុមមនុស្សចាស់ ( ៦៥ ឆ្នាំឡើង ): មាន ៦% នៃប្រជាជនសរុប ស្មើនឹងប្រមាណ ៨០.៥ ពាន់នាក់។



*កុមារទីម័រខាងកើត*



*យុវជនទីម័រខាងកើត*

## គ. សូចនាករប្រជាសាស្ត្រផ្សេងទៀត (ឆ្នាំ ២០២២)

- អត្រាភេទ: ១០៣ នាក់ មានន័យថា មានបុរសចំនួន ១០៣នាក់ ក្នុងចំណោមស្ត្រី ១០០នាក់។
- ចំនួនប្រជាជនក្មេង: ១១,៩% មានអាយុក្រោម ៥ ឆ្នាំ ហើយ ៦៤,៦% មានអាយុក្រោម ៣០ ឆ្នាំ។
- កម្រិតលទ្ធភាពបង្កកំណើតរបស់ស្ត្រីទីម័រមាន ៣ នាក់។
- អាយុសង្ឃឹមរស់ពីកំណើត: ប្រមាណ ៦៩ ឆ្នាំ ក្នុងនោះ បុរសមាន ៦៧ ឆ្នាំ និងស្ត្រីមាន ៧១ ឆ្នាំ។
- អត្រាអក្ខរកម្ម (អាយុ ១០ ឆ្នាំឡើង): ប្រមាណ ៧២.៤%។
- អត្រាកំណើនប្រជាជនប្រចាំឆ្នាំជាមធ្យម ១.៨%។
- ប្រជាជនរស់នៅទីក្រុង: ប្រហែល ២៨.៦%។




*ពីរ៉ាមីតបង្ហាញពីអាយុប្រជាជននៃប្រទេសទីម័រខាងកើត (ជំរឿនឆ្នាំ២០២២)*

### ៤.៤- វប្បធម៌

នៅទីម័រខាងកើត វប្បធម៌មិនមែនជាអ្វីដែលអ្នកអាចសង្កេតមើលពីចម្ងាយនោះទេ វាជាអ្វីដែលអ្នកអាចមានអារម្មណ៍ ការចែករំលែក និងទទួលបានបទពិសោធន៍ផ្ទាល់ពីប្រជាជនដែលរស់នៅជាមួយវាជារៀងរាល់ថ្ងៃ។ ចាប់ពីពិធីសាសនាដ៏ពិសិដ្ឋ និងការត្បាញបែបប្រពៃណី រហូតដល់ជីវិតរស់នៅភូមិ និងពិធីបុណ្យដ៏រស់រវើក ទីនេះគឺជាកន្លែងដែលបេតិកភណ្ឌត្រូវបានចាក់បញ្ចូលក្នុងចង្វាក់ជីវិតប្រចាំថ្ងៃ។ ទីម័រខាងកើតមានភាពលេចធ្លោជាគោលដៅទេសចរណ៍ដែលត្រូវបានកសាងឡើងដោយការតស៊ូ ប្រពៃណីខាងជំនឿដ៏សម្បូរបែប និងសហគមន៍ជនជាតិដើមភាគតិចចម្រុះ។ ទោះបីជាបច្ចុប្បន្នជាប្រទេសមួយក្នុងចំណោមប្រទេសដែលទទួលបាន

ភ្ញៀវទេសចរតិចបំផុតនៅអាស៊ីអាគ្នេយ៍ក៏ដោយ ក៏វាផ្តល់ឱកាសដ៏កម្រមួយសម្រាប់អ្នកទេសចរក្នុងការភ្ជាប់ទំនាក់ទំនងជាមួយវប្បធម៌រស់រវើកដែលមិនមានការប្រែប្រួល មានឫសគល់ដ៏យូរអង្វែង និងត្រូវបានចែករំលែកយ៉ាងកក់ក្តៅ។

ប្រជាជនទីម័រមានភាពរាក់ទាក់ ចូលចិត្តសេពគប់ និងជាមនុស្សដែលរួសរាយរាក់ទាក់បំផុតដែលអ្នកមិនធ្លាប់បានជួប។ ពិធីបុណ្យដែលប្រារព្ធធ្វើឡើងនៅថ្នាក់ជាតិនិងថ្នាក់សហគមន៍មានច្រើននិងរស់រវើក។ សង្គមទីម័រក៏មានលក្ខណៈអភិរក្សនិយមនិងប្រពៃណីនិយមជាមួយនឹងការផ្តោតខ្លាំងលើគ្រួសារ សហគមន៍ និងសាសនា។ ជាមួយនឹងចំនួនប្រជាជនប្រមាណ ១.៣៤ លាននាក់ ប្រជាជនទីម័រមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ទន្ទឹមនឹងនេះ អត្តសញ្ញាណរបស់ប្រទេសនេះត្រូវបានផ្សំឡើងដោយក្រុមជនជាតិដើមភាគតិចជាច្រើន ដែលក្រុមជនជាតិនីមួយៗមានភាសា និងទំនៀមទម្លាប់វប្បធម៌រៀងៗខ្លួន។ ជនជាតិតេទុម( Tetum ) គឺជាក្រុមធំជាងគេដែលគ្របដណ្តប់ប្រហែល ២៥% នៃចំនួនប្រជាជន។ ពួកគេរស់នៅជុំវិញក្រុងឌីលី( Dili ), ស៊ូអាអ៊ី ( Suai ) និងវីកេកេ( Viqueque )។ ជនជាតិម៉ាំបាអៀ( Mambae ) បង្កើតបាន ១០% បន្ថែមទៀតហើយត្រូវបានរកឃើញនៅតំបន់ភ្នំកណ្តាល។ ក្រុមផ្សេងទៀតរួមមាន កេម៉ាក( Kemak ), ប៊ូណាក់( Bunak ) និង ហ្វាតាឡុគូ ( Fataluku ) ដែលនីមួយៗមានចំនួន ៥% ឬតិចជាងនេះ។

ទីម័រខាងកើត មានភាសាដែលត្រូវបាននិយាយជាច្រើន ភាសាតេទុម( Tetum ) និងភាសាព័រទុយហ្គាល់ ( Portuguese ) ត្រូវបានផ្តល់ឋានៈជាភាសាផ្លូវការ ដោយភាសាឥណ្ឌូណេស៊ី( Indonesian ) និងអង់គ្លេស ( English ) ត្រូវបានចាត់ទុកជាភាសាសម្រាប់ប្រើប្រាស់ការងារ។ ភាសាជនជាតិដើមចំនួនដប់ប្រាំមួយ ឬច្រើនជាងនេះទៀតក៏ត្រូវបាននិយាយផងដែរ។



*សម្លៀកបំពាក់ប្រពៃណីរបស់ប្រជាជនទីម័រខាងកើត*

រដ្ឋធានីឌីលី គឺជាទីក្រុងអភិវឌ្ឍន៍ទំនើបដែលផ្តល់សេវាកម្មនិងភាពងាយស្រួលជាច្រើនសម្រាប់អ្នករស់នៅនិងភ្ញៀវទេសចរ។ ខណៈដែលប្រជាជនទីម័រជាច្រើនត្រូវបានទាក់ទាញមកកាន់រដ្ឋធានី ដើម្បីស្វែងរកការងារធ្វើ ខណៈប្រជាជន ៧០% នៅតែរស់នៅក្នុងតំបន់ជនបទ។ ប្រជាជនទីម័រទាំងនេះភាគច្រើនរស់នៅក្នុងទីក្រុងតូចៗ និងភូមិដាច់ស្រយាល ហើយប្រកបរបរនេសាទនិងកសិកម្មចិញ្ចឹមជីវិត។

ប្រជាជនទីម័រភាគច្រើនលើសលប់ប្រកាន់យកសាសនារ៉ូម៉ាំងកាតូលិក( Roman Catholic) ទោះបីជាយ៉ាងនេះក្តី ជំនឿជីវចលនិយម( animism) ឬជំនឿដើមរបស់ក្រុមជនជាតិនៅទីម័រខាងកើត នៅតែបន្តមានឥទ្ធិពលក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជនភាគច្រើន។ ការសង្កេតមើលពីរបៀបដែលជំនឿជីវចលនិយម និងជំនឿសាសនាត្រូវបានលាយបញ្ចូលគ្នាយ៉ាងរលូន គឺជាទិដ្ឋភាពដ៏គួរឱ្យចាប់អារម្មណ៍មួយនៃវិស័យទេសចរណ៍ក្នុងប្រទេសនេះ។

បេតិកភណ្ឌវប្បធម៌របស់ទីម័រមានលក្ខណៈចម្រុះ ដែលជាការរួមបញ្ចូលគ្នាយ៉ាងគួរឱ្យទាក់ទាញរវាងឥទ្ធិពលរបស់ជនជាតិទីម័រ ព័រទុយហ្គាល់ និងឥណ្ឌូណេស៊ី។ នេះបានជ្រួតជ្រាបនៅក្នុងស្ថាបត្យកម្មក្នុងស្រុក ម្ហូបអាហារ រចនាបទសម្លៀកបំពាក់ និងកិច្ចខិតខំប្រឹងប្រែងផ្នែកសិល្បៈរបស់ពួកគេ។ វប្បធម៌ទីម័របន្តវិវឌ្ឍនៅក្នុងសិល្បៈនិងសិប្បកម្ម ក៏ដូចជានៅក្នុងការរាំនិងតន្ត្រីក្នុងស្រុក។ ធាតុវប្បធម៌ទាំងចាស់និងថ្មីត្រូវបានដាក់បញ្ចូលទៅក្នុងគំរូនៃការរចនានៃ តៃស៍( tais) ដែលជាវាយនភ័ណ្ឌត្បាញដោយដៃ កញ្ចែងត្បាញ និងចម្លាក់ឈើ។ ក្រុមវប្បធម៌នៅតែបន្តសម្តែងរបាំនិងចម្រៀងប្រពៃណី ហើយក៏កំពុងកម្សាន្តតាមកម្មវិធីថ្មីៗផងដែរ។ ក្រុមតន្ត្រីនិងរបាំដែលមានទេពកោសល្យរបស់ទីម័របានសម្តែងនៅក្នុងតំបន់និងនៅតាមពិធីបុណ្យនានា។ មានភាពចម្រុះផ្នែកស្ថាបត្យកម្មជាច្រើននៅក្នុងប្រទេសទីម័រខាងកើត ដោយសារក្រុមជនជាតិនីមួយៗមានប្រពៃណីនិងទំនៀមទម្លាប់រៀងៗខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ស្ថាបត្យកម្មស្ទើរតែទាំងអស់ត្រូវបានសាងសង់ពីឈើ ដូច្នេះមានអគារតិចតួចប៉ុណ្ណោះដែលនៅសេសសល់រហូតដល់បច្ចុប្បន្ន ហើយអ្វីដែលឈរនៅសព្វថ្ងៃភាគច្រើនគឺមកពីសតវត្សចុងក្រោយ ក្រៅពីសំណង់ពីរបីប៉ុណ្ណោះ។ ស្ថាបត្យកម្មដើមនិងនៅតែជាប្រពៃណីល្អបំផុតនៅក្នុងប្រទេសទីម័រខាងកើតគឺផ្ទះតូតឹម( totem house)។ ឧទាហរណ៍នៃសំណង់ទាំងនេះត្រូវបានរកឃើញនៅទូទាំងប្រទេស ប៉ុន្តែមានលក្ខណៈខុសគ្នាតាមតំបន់និងប្រវត្តិជនជាតិ។ អ៊ូម៉ា លូលីក ( Uma Lulik) ឬ ក៏ត្រូវបានគេហៅថាជាផ្ទះវិញ្ញាណផងដែរ ពីព្រោះវាផ្ទុកវិញ្ញាណរបស់បុព្វបុរសនៃគ្រួសារដែលជាម្ចាស់វា។ ផ្ទះទាំងនោះត្រូវបានសាងសង់ឡើងវិញរៀងរាល់ដប់ឆ្នាំម្តងដើម្បីជួយបន្តការតភ្ជាប់របស់សហគមន៍ទៅនឹងបុព្វបុរសនិងទឹកដីរបស់ខ្លួន។ ម្យ៉ាងវិញទៀត ក៏មានអគារបែបព័រទុយហ្គាល់តិចតួចដែរនៅក្នុងប្រទេសទីម័រខាងកើត ដែលជាកេរដំណែលរបស់ព័រទុយហ្គាល់។ អគារភាគច្រើននៃរចនាបថនេះ គឺជាព្រះវិហារឬអគារនៅក្នុងរដ្ឋធានីឌីលី។ បន្ទាប់ ពីរចនាបទព័រទុយហ្គាល់ក្នុងការសាងសង់ពីថ្ម បេតុង និងសារធាតុរឹងផ្សេងទៀត បច្ចុប្បន្នប្រទេសនេះមានអគារទំនើបមួយចំនួនដែលភាគច្រើនធ្វើពីបេតុងនិងកញ្ចក់។

នៅក្នុងប្រទេសទីម័រខាងកើត ជីវិតភូមិបែបប្រពៃណីត្រូវបានផ្តោតលើ "aldeia" ដែលជាសហគមន៍ជនបទដែលមានទំនាក់ទំនងជិតស្និទ្ធ ជាកន្លែងដែលចង្វាក់ជីវិតប្រចាំថ្ងៃធ្វើតាមវដ្តនៃធម្មជាតិ ពិធីសាសនា និងការទទួលខុសត្រូវរួម។ ភូមិទាំងនេះគឺជាបេះដូងដ៏រស់រវើកនៃវប្បធម៌ទីម័រ ដែលជាកន្លែងដែលការនិទានរឿងតាមមាត់ ពិធីតាមរដូវកាល និងការងាររួមបន្តរៀបចំអត្តសញ្ញាណ និងការតភ្ជាប់គ្នារវាងប្រជាជន។ នៅចំ

កណ្ដាលភូមិជាច្រើនមាន អ៊ូម៉ា លូលីក( Uma Lulik ) ឬផ្ទះពិសិដ្ឋ ដែលជាមជ្ឈមណ្ឌលខាងជំនឿដែលតំណាងឱ្យការតភ្ជាប់របស់សហគមន៍ទៅនឹងបុព្វបុរសនិងទឹកដីរបស់ខ្លួន។ សំណង់ដែលសាងសង់ពីសម្ភារៈធម្មជាតិដូចជាឈើនិងស្លឹកត្នោត មិនមែនគ្រាន់តែជាលក្ខណៈស្ថាបត្យកម្មប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានចាត់ទុកថាជានិមិត្តសញ្ញារស់រវើកនៃអត្តសញ្ញាណវប្បធម៌។ ផ្ទះទាំងនេះផ្ទុកវត្ថុពិសិដ្ឋ ធ្វើជាកន្លែងសម្រាប់រៀបចំពិធីសំខាន់ៗ និងបម្រើជាកន្លែងសម្រាប់ដោះស្រាយជម្លោះនិងធ្វើការសម្រេចចិត្តរួម។ ពិធីសំខាន់ៗក្នុងជីវិតភូមិរួមមានពិធីដែលទាក់ទងនឹងកសិកម្ម ដូចជាការបន់ស្រន់មុនពេលដាំដុះឬប្រមូលផល និងពិធីឆ្លងជីវិតដូចជាការប្រារព្ធពិធីកំណើតនិងការគោរពបុព្វបុរស។ ពិធីទាំងនេះតែងតែលាយបញ្ចូលគ្នានូវជំនឿជីវចលនិយមជាមួយប្រពៃណីកាតូលិក ដែលឆ្លុះបញ្ចាំងពីលក្ខណៈនៃការរួមបញ្ចូលគ្នានៃជំនឿរបស់ប្រជាជនទីម័រ។



*ផ្ទះអ៊ូម៉ា លូលីក (Uma Lulik ) ជាផ្ទះពិសិដ្ឋក្នុងជំនឿដើមរបស់ប្រជាជនទីម័រខាងកើត*

### ៤.៥- សាសនា

ទីម័រខាងកើតគឺជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួននៅអាស៊ីដែលប្រជាជនភាគច្រើនកាន់សាសនាគ្រិស្ត( ៩៩.៤% ) ដែលភាគច្រើនជាអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិក ( ៩៧,៥% គិតត្រឹមឆ្នាំ ២០២២ ) ។ ប្រហែល ១.៩% កាន់និកាយប្រូតេស្តង់ ប្រជាជនដែលនៅសល់កាន់សាសនាឥស្លាម ( ០,៣% ) និងសាសនាផ្សេងទៀត ( ០,៣% )។

យោងតាមរដ្ឋធម្មនុញ្ញរបស់ទីម័រខាងកើត( ឆ្នាំ ២០០២ ) សេរីភាពក្នុងការកាន់សាសនា និងការគោរពបូជាត្រូវបានធានា រួមជាមួយការហាមឃាត់ការរើសអើងដោយផ្អែកលើជំនឿសាសនា។ មានការបែងចែកជាផ្លូវការរវាងរដ្ឋនិងសាសនា មានន័យថាគ្មានសាសនារដ្ឋផ្លូវការទេ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះវិហារកាតូលិកនៅតែបន្តដើរតួនាទីសំខាន់ក្នុងប្រវត្តិសាស្ត្រ នយោបាយ សង្គម និងវប្បធម៌របស់ទីម័រខាងកើត។ ជាឧទាហរណ៍ ថ្នាក់ដឹកនាំសាសនាកាតូលិកតែងតែដឹកនាំពិធីរដ្ឋាភិបាល។

សាសនាគ្រិស្តត្រូវបាននាំចូលមកកោះទីម័រនៅដើមសតវត្សទី ១៦ តាមរយៈឈ្មួញហូឡង់និងព័រទុយហ្គាល់។ បន្ទាប់មកភ្លាមៗ ក្រុមអ្នកផ្សព្វផ្សាយសាសនាកាតូលិកពីប្រទេសព័រទុយហ្គាល់បានមកដល់។ ទោះបីជាផ្នែកខ្លះនៃប្រជាជនទីម័រខាងកើតបានប្រែចិត្តជឿមកកាន់សាសនាគ្រិស្តក្នុងអំឡុងពេលនោះក៏ដោយ ក៏មនុស្សជាច្រើននៅតែបន្តការអនុវត្តប្រពៃណីសាសនាក្នុងស្រុករបស់ពួកគេ។ នៅសតវត្សទី ២០ មានការកើនឡើងជាលំដាប់នៃអ្នកប្រែចិត្តជឿមកកាន់សាសនាកាតូលិក។ ការកើនឡើងនេះបានកើនឡើងយ៉ាងឆាប់រហ័សនៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៩០ ក្នុងអំឡុងពេលដែលឥណ្ឌូណេស៊ីបានចូលកាន់កាប់ទីម័រខាងកើតបន្តពីព័រទុយហ្គាល់នៅឆ្នាំ ១៩៧៥។ ខណៈដែលប្រហែល ២០-៣០% នៃប្រជាជនកាន់សាសនាកាតូលិកនៅឆ្នាំ ១៩៧៥ ចំនួននេះបានកើនឡើងដល់ប្រហែល ៩០% នៅឆ្នាំ ១៩៩៤។ គិតត្រឹមឆ្នាំ ២០២២ មាន ៩៧,៥% (ប្រជាជនប្រហែល ១,៣ លាននាក់) កាន់សាសនារ៉ូម៉ាំងកាតូលិក។

ចាប់តាំងពីការមកដល់របស់ខ្លួន ព្រះវិហារកាតូលិកបានដើរតួនាទីយ៉ាងសំខាន់ក្នុងប្រវត្តិសាស្ត្រនយោបាយរបស់ទីម័រខាងកើត។ ក្នុងឱកាសជាច្រើន ព្រះវិហារបានឈរនៅខាងប្រជាជនទីម័រខាងកើតប្រឆាំងនឹងរបបអាណានិគម ដែលបណ្ដាលឱ្យព្រះវិហារត្រូវបានបណ្ដេញចេញពីទឹកដីអាណានិគមមួយរយៈពេល។ ក្នុងអំឡុងពេលការកាន់កាប់របស់ឥណ្ឌូណេស៊ី សមាជិកជាច្រើននៃព្រះវិហារកាតូលិកដូចជាបូជាចារ្យនិងដូនជីបានតស៊ូមតិដើម្បីសិទ្ធិមនុស្សនៅទីម័រខាងកើត និងប្រថុយជីវិតរបស់ពួកគេដើម្បីការពារប្រជាពលរដ្ឋពីការរំលោភបំពានរបស់យោធាឥណ្ឌូនេស៊ី។ ការចូលរួមរបស់ព្រះវិហារកាតូលិកក្នុងដំណើរផ្លាស់ប្ដូរនយោបាយរបស់ទីម័រខាងកើត ជាពិសេសក្នុងការសម្រេចបានឯករាជ្យភាព បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតអត្តសញ្ញាណសង្គមនិងវប្បធម៌របស់ប្រទេស។



*វិហារគ្រិស្តសាសនានៅប្រទេសទីម័រខាងកើត*

ប្រទេសទីម័រខាងកើតមានការគ្រប់គ្រងផ្នែកសាសនាកាតូលិកដោយបែងចែកជាបីភូមិភាគ (Dioceses) គឺ ភូមិភាគធំ(Archdiocese) នៃឌីលី ភូមិភាគនៃម៉ាលីអាណា និងភូមិភាគនៃបៅកៅ។ ថ្វីដ្បិតតែមានការបែង

ចែកបែបនេះក៏ដោយ ក៏វាជារឿងធម្មតាដែលយើងអាចប្រទះឃើញរូបសំណាកពួកបរិសុទ្ធ និមិត្តសញ្ញារូបឈើឆ្កាង និងព្រះវិហារជាច្រើននៅពាសពេញប្រទេស។ ពិធីបុណ្យត្រូវបានធ្វើឡើងជាញឹកញាប់ដោយប្រើភាសាព័រទុយហ្គាល់ ឬតេទុម។ ប្រជាជនតែងតែចូលរួមព្រះវិហារសម្រាប់ព្រឹត្តិការណ៍សំខាន់ៗក្នុងជីវិតផ្ទាល់ខ្លួន ដូចជាពិធីជ្រមុជទឹក ពិធីអាពាហ៍ពិពាហ៍កាតូលិក និងពិធីបុណ្យសព។ នៅកម្រិតជាតិ ថ្ងៃឈប់សម្រាកសំខាន់ៗជាច្រើនក្នុងប្រតិទិនកាតូលិក ដូចជាបុណ្យអ៊ីស្ទើរ បុណ្យណូអែល និងពិធីបុណ្យនានាដែលទាក់ទងនឹងព្រះនាងម៉ារីក៏ត្រូវបានប្រារព្ធធ្វើឡើងយ៉ាងអធិកអធមផងដែរ។

ក្រៅពីភាពពេញនិយមនៃសាសនាគ្រិស្ត ទីម័រខាងកើតគឺជាទីកន្លែងនៃជំនឿដើមក្នុងស្រុក និងជនជាតិដើមដែលសម្បូរបែប ដែលមានតាំងពីយូរលង់ណាស់មកហើយ។ ការផ្លាស់ប្ដូរប្រវត្តិសាស្ត្រនិងនយោបាយរបស់ទីម័រខាងកើតបានរំខានដល់ការអនុវត្តពិធីសាសនាបែបប្រពៃណីរបស់ក្រុមជនជាតិជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍ជាច្រើនអាចសម្របខ្លួនទៅនឹងការអនុវត្តនិងជំនឿក្នុងស្រុក និងបន្តគោរពប្រពៃណីទាំងនោះ។ ទោះបីជាមិនមានសាសនាឬជំនឿខាងវិញ្ញាណស្តង់ដារក៏ដោយ ក៏មានភាពស្រដៀងគ្នាខ្លះៗក្នុងចំណោមជំនឿដើមក្នុងស្រុកផ្សេងៗគ្នា។ រឿងសំខាន់បំផុតមួយគឺការរក្សាទំនាក់ទំនងវិជ្ជមានជាមួយភាពពិសិដ្ឋ( lulik) ដោយការធ្វើតាមនិងគោរពទំនៀមទម្លាប់និងពិធីសាសនាមួយចំនួន(គេស្គាល់ថាជា lisan)។ ការអនុវត្តបែបនេះរួមមានការធ្វើតាមទំនៀមទម្លាប់និងច្បាប់វប្បធម៌ និងការថ្វាយបង្គំទៀងទាត់ទៅកាន់អាទិទេពពិសិដ្ឋផ្សេងៗ ដូចជា ព្រះវិញ្ញាណ( rai-nain) និងបុព្វបុរស( matebian)។ ភាពពិសិដ្ឋក៏សំដៅទៅលើរបៀបដែលមនុស្សគួរតែទាក់ទងគ្នាទៅវិញទៅមក ក៏ដូចជាជាមួយបរិស្ថានរបស់ពួកគេផងដែរ។ ជាឧទាហរណ៍ ការគោរពសិទ្ធិនិងកាតព្វកិច្ចរវាងសមាជិកក្មេងៗក្នុងសហគមន៍ទៅកាន់មនុស្សចាស់។ ក្នុងនាមជាផ្នែកមួយនៃការគោរពភាពពិសិដ្ឋ វាជារឿងធម្មតាសម្រាប់សមាជិកសហគមន៍នៅតាមតំបន់ជនបទនៃប្រទេសក្នុងការប្រមូលធនធានមួយចំនួនរបស់ពួកគេជាមួយគ្នាដើម្បីសាងសង់ផ្ទះពិសិដ្ឋ (uma lulik)។ ទីកន្លែងពិសិដ្ឋបែបនេះមានមុខងារសង្គម-សាសនា និងវប្បធម៌សំខាន់ៗមួយចំនួន។ ផ្ទះពិសិដ្ឋអនុញ្ញាតឱ្យ lia-na 'in(មានន័យត្រង់ថា ម្ចាស់នៃពាក្យ សំដៅលើអ្នករក្សាច្បាប់ក្នុងស្រុកនិងបូជាចារ្យ) ធ្វើពិធីសាសនា គឺជាកន្លែងដែលជម្លោះរវាងសមាជិកសហគមន៍អាចត្រូវបានដោះស្រាយ និងជាកន្លែងដែលរឿងរ៉ាវនិងវត្ថុបុរាណដែលជាកម្មសិទ្ធិរបស់បុព្វបុរសត្រូវបានរក្សាទុក។

## ៥- ស្ថានភាពសេដ្ឋកិច្ច

សេដ្ឋកិច្ចរបស់ប្រទេសទីម័រខាងកើតមានលក្ខណៈតូច និងនៅមានការអភិវឌ្ឍតិចតួចនៅឡើយ។ បច្ចុប្បន្ន សេដ្ឋកិច្ចប្រទេសនេះពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់ចំណូលពីវិស័យប្រេងកាតនិងឧស្ម័នធម្មជាតិ ដែលជាប្រភពចំណូលដ៏សំខាន់សម្រាប់រដ្ឋាភិបាល។ ទោះបីជាមានភាពរឹងមាំខ្លះក៏ដោយ ក៏ប្រទេសនេះនៅតែប្រឈមនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរ ដូចជាភាពក្រីក្រខ្ពស់ និងភាពអត់ការងារធ្វើខ្ពស់ជាដើម។ ប្រជាជននៅទីម័រខាងកើតមានចំនួនប្រមាណ ១,៣៤១,៧៣៧ នាក់(ជំរឿនឆ្នាំ ២០២២)ដែលភាគច្រើនជាយុវវ័យ។ នេះជាសក្ដានុពលដ៏ធំមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគត។ យោងតាមទិន្នន័យពីស្ថាប័នធនាគារពិភពលោក (World Bank) តម្លៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ (GDP per capita) របស់ទីម័រខាងកើតសម្រាប់ឆ្នាំ ២០២៤ មានចំនួន ១,៣៤៣.១៥ ដុល្លារអាមេរិក។ ដោយយោងតាមរបាយការណ៍ធនាគារអភិវឌ្ឍន៍អាស៊ី

(ADB) បានឱ្យដឹងថា ផលិតផលក្នុងស្រុកសរុប(GDP) របស់ទីម័រខាងកើតនៅឆ្នាំ ២០២៣ គឺប្រហែល ២.១ ពាន់លានដុល្លារអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើយើងគិតតែលើសេដ្ឋកិច្ចក្នុងស្រុកដែលមិនរាប់បញ្ចូលប្រាក់ចំណូលពីប្រេងកាតនិងឧស្ម័នធម្មជាតិ(Non-oil GDP) វិញ ទំហំសេដ្ឋកិច្ច គឺត្រឹមតែប្រហែល ១.៨ ពាន់លានដុល្លារអាមេរិក ប៉ុណ្ណោះ។ យោងតាមរបាយការណ៍ "Timor-Leste National Accounts 2004-2023" ដែលចេញផ្សាយដោយវិទ្យាស្ថានស្ថិតិជាតិនៃប្រទេសទីម័រខាងកើត(INETL) ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសទីម័រខាងកើតក្នុងឆ្នាំ ២០២៣ វិស័យសេវាកម្ម(ទេសចរណ៍ ពាណិជ្ជកម្ម និងគមនាគមន៍) បានក្លាយជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចដ៏សំខាន់ ដោយបានរួមចំណែកដល់ទៅប្រមាណ ៦១.០១%។ ចំណែកឯវិស័យឧស្សាហកម្មវិញ បានចូលរួមចំណែកប្រមាណ ២៣.៨៧% ខណៈដែលវិស័យកសិកម្មបានរួមចំណែក ១៦.៨៦%។ តួលេខទាំងនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា វិស័យសេវាកម្មគឺជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចរបស់ទីម័រខាងកើតនាពេលបច្ចុប្បន្ន។ ប្រទេសទីម័រខាងកើតប្រើប្រាស់រូបិយប័ណ្ណរបស់សហរដ្ឋអាមេរិក គឺប្រាក់ដុល្លារ (United States Dollar) ជាផ្លូវការ។ ទន្ទឹមនឹងនេះ ធនាគារកណ្ដាលរបស់ទីម័រខាងកើត ក៏បានចេញផ្សាយរូបិយវត្ថុ(កាក់) ផ្ទាល់ខ្លួនដែលមានឈ្មោះថា សង់តាវ៉ូស(Centavos) ដើម្បីប្រើប្រាស់រួមគ្នាជាមួយនឹងក្រដាសប្រាក់ដុល្លារអាមេរិក។ កាក់សង់តាវ៉ូសមួយមានតម្លៃស្មើនឹងមួយសេនអាមេរិក(1 centavos = 1 U.S. cent)។




*ផលិតផលក្នុងស្រុកសរុប(GDP) នៃប្រទេសទីម័រខាងកើត (ពីឆ្នាំ២០១៣ ឆ្នាំ២០២៣)*

### ៥.១- វិស័យប្រេងកាត ឧស្ម័នធម្មជាតិ និងរ៉ែ

ឧស្សាហកម្មប្រេងកាត និងឧស្ម័នធម្មជាតិ ដើរតួនាទីយ៉ាងសំខាន់ និងជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់ប្រទេសទីម័រខាងកើត។ ប្រាក់ចំណូលភាគច្រើនរបស់ប្រទេសនេះបានមកពីធនធានធម្មជាតិទាំងនេះ ដែលបានរួមចំណែកយ៉ាងធំធេងដល់កំណើនសេដ្ឋកិច្ច។ ប្រាក់ចំណូលដែលបានមកពីការលក់ប្រេងកាត និងឧស្ម័នធម្មជាតិ ត្រូវបានដាក់បញ្ចូលទៅក្នុងមូលនិធិប្រេងកាត(Petroleum Fund) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ

២០០៥។ គោលបំណងនៃមូលនិធិនេះ គឺដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង ការចំណាយរបស់រដ្ឋាភិបាលនាពេលអនាគត និងជាមូលដ្ឋានគ្រឹះសម្រាប់ការវិនិយោគលើវិស័យផ្សេងៗទៀត។ យោងតាមរបាយការណ៍ជាតិ វិស័យប្រេងនៅទីម័រខាងកើតបានរួមចំណែកយ៉ាងសំខាន់ដល់ GDP ក្នុងឆ្នាំ ២០២៣ ក៏ប៉ុន្តែមានការធ្លាក់ចុះយ៉ាងខ្លាំងប្រមាណ ៧៤,៨%។ ការធ្លាក់ចុះនេះបណ្ដាលមកពីការថយចុះយ៉ាងគំហុក ៦០,៨% នៃផលិតកម្មប្រេង។ គិតត្រឹមដំណាច់ឆមាសទី១ ក្នុងឆ្នាំ ២០២៥ មូលនិធិប្រេងកាតមានទឹកប្រាក់ប្រហែល ១៨.៧៥ ពាន់លានដុល្លារអាមេរិក។ ក្នុងនោះប្លុកប្រេងបាយូ-អ៊ុនដាន(Bayu-Undan) ដែលបានចាប់ផ្ដើមផលិតតាំងពីឆ្នាំ ២០០៤ ជាប្រភពចំណូលដ៏សំខាន់មួយ ប៉ុន្តែប្លុកនេះបានរីងស្ងួត។ ហើយបើយោងតាមសេចក្ដីប្រកាសព័ត៌មានពីអាជ្ញាធរជាតិប្រេងឥន្ទនៈ(Autoridade Nacional do Petróleo, I.P.) បានបញ្ជាក់ថា ការផលិតនៅប្លុកប្រេង Bayu-Undan ត្រូវបានបញ្ចប់ជាផ្លូវការនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ ២០២៥។ ការធ្លាក់ចុះនេះបានធ្វើឱ្យសេដ្ឋកិច្ចទីម័រខាងកើតប្រឈមនឹងបញ្ហាយ៉ាងខ្លាំង ព្រោះការចំណាយរបស់រដ្ឋាភិបាលបានពឹងផ្អែកខ្លាំងទៅលើការដកប្រាក់ពីមូលនិធិនេះ ហើយការដកប្រាក់ក៏បានលើសកម្រិតនិរន្តរភាពស្ទើរតែគ្រប់ឆ្នាំចាប់តាំងពីឆ្នាំ ២០០៩ មក។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ រដ្ឋាភិបាលទីម័រខាងកើតកំពុងជំរុញឱ្យមានការអនុម័តចុងក្រោយនៃក្របខ័ណ្ឌកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលអូស្ត្រាលី ដើម្បីបូមយកប្រេងកាតនិងឧស្ម័នធម្មជាតិក្នុងប្លុកប្រេងហ្គ្រេតធ័រសាន់រ៉ាយ(Greater Sunrise) ដែលមានទីតាំងនៅសមុទ្រទីម័រ។ ប្លុកនេះមានឧស្ម័នធម្មជាតិប្រមាណ ៥.១ ពាន់លានហ្វីតគូប ហើយគម្រោងនេះត្រូវបានគេរំពឹងថានឹងចាប់ផ្ដើមផលិតនៅចន្លោះឆ្នាំ ២០២៨-២០៣០។

ប្រទេសទីម័រខាងកើតត្រូវបានគេជឿថា មានសក្ដានុពលធនធានរ៉ែសំខាន់ៗផ្សេងទៀតផងដែរ ដូចជារ៉ែមាស ក្រូមីត(chromite) ដែក សំណប៉ាហាំង និងធនធានរ៉ែដទៃទៀត។ ទោះជាយ៉ាងណាក៏ដោយ វិស័យរ៉ែមិនទាន់ត្រូវបានអភិវឌ្ឍន៍ទាញយករ៉ែទាំងនោះនៅឡើយទេ ហើយការរុករក និងការទាញយករ៉ែនៅមានកម្រិតទាប។ រដ្ឋាភិបាលកំពុងចាប់ផ្ដើមសិក្សា និងរៀបចំផែនការដើម្បីទាញយកសក្ដានុពលពីវិស័យរ៉ែ ដើម្បីអាចពង្រឹងសេដ្ឋកិច្ចឱ្យមានភាពចម្រុះ និងកាត់បន្ថយការពឹងផ្អែកលើវិស័យប្រេងកាត។ ការអភិវឌ្ឍវិស័យប្រេងកាតនិឧស្ម័នធម្មជាតិ ក៏ដូចជាវិស័យរ៉ែ អាចបង្កផលប៉ះពាល់ដល់បរិស្ថានផងដែរ ប្រសិនបើគ្មានការគ្រប់គ្រងត្រឹមត្រូវ។ ម្យ៉ាងវិញទៀត ទីម័រខាងកើតនៅតែមានកង្វះខាតធនធានមនុស្សដែលមានជំនាញខ្ពស់ក្នុងវិស័យនេះ។

### ៥.២- វិស័យកសិកម្ម

នៅឆ្នាំ ២០២៣ វិស័យកសិកម្មនៅទីម័រខាងកើតបានរួមចំណែកដល់ ១៦,៨៦% នៃផលិតផលក្នុងស្រុកសរុប(GDP)។ លទ្ធផលនៃជំរឿនកសិកម្មឆ្នាំ ២០១៩ បានបង្ហាញថា គ្រួសារចំនួន ១៤១,១៤១ ដែលស្មើនឹង ៦៦% នៃចំនួនគ្រួសារសរុបទូទាំងប្រទេស(២១៣,៤១៧ គ្រួសារ) រស់នៅពឹងផ្អែកលើកសិកម្ម។ របាយការណ៍មួយផ្សេងទៀតក៏បានលើកឡើងផងដែរថា ប្រជាជនជាង ៨០% ចូលរួមក្នុងសកម្មភាពផលិតកម្មកសិកម្ម តែបច្ចុប្បន្ននេះ កំពុងមាននិន្នាការថយចុះបន្តិចបន្តួច។ ស្ថិតិទាំងនេះ បានបង្ហាញថាមានសក្ដានុពលដ៏ធំធេងសម្រាប់កំណើន ការធ្វើពិពិធកម្ម ការផ្លាស់ប្ដូរ និងការវិនិយោគនៅក្នុងវិស័យកសិកម្មទីម័រខាកើត។ ឱកាសវិនិយោគមានច្រើន ជាពិសេសក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម និងកែច្នៃកសិផលសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។



*វាលស្រែនៅប្រទេសទីម័រខាងកើត*

យោងតាមប្រភពពី CIA World Factbook ដែលបានធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីធ្លីនៅទីម័រខាងកើតនៅឆ្នាំ២០២២ ដីកសិកម្មមាន ២៣% (ដីដាំដំណាំអចិន្ត្រៃយ៍មាន ៥,៤% ដីដាំដំណាំតាមរដូវមាន ៧,៥% និងដីវាលស្មៅសម្រាប់ចិញ្ចឹមសត្វមាន ១០,១%) ដីព្រៃឈើមាន ៦១,៨% និងដីផ្សេងៗទៀត ១៥,៣%។




Source: DGE-MoF, Timor-Leste Agriculture Census: 2019 (p.37)

ផ្ទៃដីកសិកម្មសរុបដែលត្រូវបានដាំដុះនៅទីម័រខាងកើតមានប្រហែល ៥០៩,២២៦ ហិកតា។ ដំណាំ និងរុក្ខជាតិចំនួន ៧២ ប្រភេទត្រូវបានដាំដុះ ដែលក្នុងនោះដំណាំធំៗចំនួន ១៣ ប្រភេទត្រូវបានដាំដុះស្មើនឹង ៧០% នៃផ្ទៃដីដាំដុះសរុបក្នុងប្រទេស។ ដំណាំទាំងនោះរួមមាន ពោត(១៨%) ស្រូវ(៧,៦%) ដំឡូងមី (៧,៤%) កាហ្វេ(៦,៣%) ដូង(៥,៨%) ចេក(៥,៤%) ដើមម៉ៃសាក់(៤,២%) ស្វាយ(៣,៦%) ដំឡូងជ្វា (២,៨%) ល្ហុង(២,៤%) ដើមទៀន(២,២៩%) ត្រាវ(២,២៩%) និងស្លា(១,៩%)។ ដំណាំ និងរុក្ខជាតិចំនួន ៥៩ ដែលនៅសល់មានចំនួន ៣០% នៃផ្ទៃដីដាំដុះសរុប។



*ដំណាំកាហ្វេនៅទីម័រខាងកើត*

កសិផលសំខាន់ៗសម្រាប់ទីផ្សារក្នុងស្រុក និងក្រៅស្រុករួមមាន កាហ្វេ អង្ករ ពោត សណ្ដែក ការ៉ុត ដំឡូងមី ដើមឈើអែម ផ្កាក្លាំពូ ដំឡូងបារាំង ដើមខ្លឹមចន្ទន៍ក្រឹស្នា តារ៉ូ និងដំណាំសាកវប្បកម្មសរីរាង្គ(ផ្លែឈើ បន្លែ ស្វាយចន្ទី កាការ ប្រេងដូង និងវ៉ានីឡា)។ នៅឆ្នាំ ២០១៥ មានគ្រួសារប្រហែល ១៦៣,០០០ គ្រួសារ នៅក្នុងប្រទេសទីម័រខាងកើតដែលផលិតដំណាំ(ជាចម្បងសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង)។ ជាមួយគ្នានោះដែរ វិស័យជលផលក៏មានសារៈសំខាន់ផងដែរ ដោយ ៩៤% នៃការចាប់ត្រីក្នុងស្រុកបានមកពីការនេសាទនៅតាមឆ្នេរ។

សក្ដានុពលកសិកម្មរបស់ទីម័រខាងកើតអាចត្រូវបានគេមើលឃើញយ៉ាងច្បាស់នៅក្នុងការផលិត និងការនាំចេញកាហ្វេនាពេលបច្ចុប្បន្ន។ កាហ្វេគឺជាមុខទំនិញនាំចេញមិនមែនប្រេងដ៏សំខាន់របស់ទីម័រ ដែលមាន

ដំណើរការល្អ និងផ្តល់ផលចំណេញខ្ពស់ទាំងនៅក្នុងទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ស្ថាប័នឧស្សាហកម្មដូចជា សមាគមកាហ្វេទីម័រខាងកើត ធ្វើការដើម្បីកែលម្អស្តង់ដារគុណភាព និងពង្រឹងម៉ាកយីហោកាហ្វេទីម័រ។ ក្នុងឆ្នាំ ២០២០ កាសែត Macau Post បានគូសបញ្ជាក់នៅក្នុងការបោះពុម្ពផ្សាយព័ត៌មានរបស់ខ្លួនថា កាហ្វេទីម័រខាងកើតសុទ្ធសាធមានរសជាតិឆ្ងាញ់ ហើយកាហ្វេលាមកសំពោចរបស់ទីម័រខាងកើតមានគុណភាពខ្ពស់។ ដោយសារតែគុណភាពនេះ ប្រទេសតូចៗដូចជាទីម័រខាងកើតបានទទួលជោគជ័យយ៉ាងធំធេងនៅក្នុងពិព័រណ៍ផលិតផលនាំចូលអន្តរជាតិចិនលើកទី៣ (CIIE) ខណៈដែលអ្នកទស្សនាបន្តតម្រង់ជួរនៅមុខស្តង់ដើម្បីភ្លក្សរសជាតិកាហ្វេក្រូចឆ្មារពីទីម័រខាងកើត ដែលត្រូវបានផលិត និងបម្រើដោយបារីស្តានៅនឹងកន្លែង។

រដ្ឋាភិបាលទីម័រខាងកើតគាំទ្រអ្នកវិនិយោគនៅក្នុងវិស័យកសិកម្ម ដោយបានចែកជូនដល់កសិករនូវគ្រាប់ពូជដែលមានគុណភាពល្អ ការបណ្តុះបណ្តាលបច្ចេកទេសថ្មីៗ និងឧបករណ៍កសិកម្មទំនើប។ គម្រោងមូលនិធិហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ កំពុងជួយជំរុញការផលិត ការចែកចាយ និងធានាសន្តិសុខស្បៀងនៅក្នុងប្រទេស។ គម្រោងនេះបានបញ្ចប់រួចរាល់ហើយនៅតំបន់រ៉ៃបេរ៉េ(Raibere), អូបាបា(Oebaba), ការ៉ៅលូន(Carauln), បេប៊ុយ(Bebui) និងតំបន់កាសាមេតា(Cassameta) ហើយក៏មានគម្រោងធារាសាស្ត្រកំពុងបន្តចំនួនប្រាំពីរទៀតផងដែរ។ ដោយសារតែមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនភាពងាយស្រួលដល់តំបន់ដាច់ស្រយាល និងមានជំនួយបរទេសរួមទាំងជំនួយបច្ចេកទេសដើម្បីពង្រឹងជំនាញកសិករ វិស័យកសិកម្មនៅប្រទេសទីម័រខាងកើតកំពុងមានការផ្លាស់ប្តូរពីការធ្វើកសិកម្មបែបបុរាណនិងសម្រាប់តែចិញ្ចឹមជីវិតទៅជាការអភិវឌ្ឍន៍ឆ្ពោះទៅរកពាណិជ្ជកម្មច្រើនជាងមុន។

ទោះជាយ៉ាងណា ដោយសារតែទីតាំងភូមិសាស្ត្ររបស់ខ្លួន ទីម័រខាងកើតងាយរងគ្រោះនឹងគ្រោះធម្មជាតិដូចជា ទឹកជំនន់ ការបាក់ដី ការរញ្ជួយដី ស៊ូណាមី និងព្យុះស៊ីក្លូនជាដើម ដែលអាចបង្កជាផលប៉ះពាល់ដល់វិស័យកសិកម្ម។

### ៥.៣- វិស័យឧស្សាហកម្ម

យោងតាមរបាយការណ៍ Timor-Leste's National Accounts 2004-2023 ដែលចេញផ្សាយដោយអគ្គនាយកដ្ឋានស្ថិតិ(DGS) នៃប្រទេសទីម័រខាងកើត។ នៅឆ្នាំ ២០២៣ ការរួមចំណែករបស់វិស័យឧស្សាហកម្មក្នុងផលិតផលក្នុងស្រុកសរុប(GDP) របស់ប្រទេសទីម័រខាងកើតអាចត្រូវបានបែងចែកជាពីរប្រភេទគឺ ឧស្សាហកម្មមិនមែនប្រេង និងឧស្សាហកម្មប្រេង។ ឧស្សាហកម្មមិនមែនប្រេងដូចជា ឧស្សាហកម្មផលិតកម្ម(ដូចជាសិប្បកម្ម និងការកែច្នៃ) សំណង់ និងប្រភេទឧស្សាហកម្មផ្សេងៗទៀតបានរួមចំណែកប្រមាណ ១០.៥% នៃ GDP។ តួលេខនេះឆ្លុះបញ្ចាំងពីទំហំពិតប្រាកដនៃឧស្សាហកម្មក្នុងស្រុកដែលមិនពាក់ព័ន្ធនឹងធនធានធម្មជាតិ។ ប្រសិនបើបូកបញ្ចូលចំណូលពីឧស្សាហកម្មប្រេងកាត និងឧស្ម័នធម្មជាតិ ដែលជាប្រភពចំណូលដ៏សំខាន់របស់ប្រទេស នោះវិស័យឧស្សាហកម្មសរុបបានរួមចំណែកប្រហែល ២៣.៨៧% នៃផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសទីម័រខាងកើត។ តួលេខនេះបង្ហាញយ៉ាងច្បាស់អំពីឥទ្ធិពលដ៏ធំធេងនៃឧស្សាហកម្មប្រេងកាត និងឧស្ម័នធម្មជាតិទៅលើសេដ្ឋកិច្ចរបស់ប្រទេស។

យោងតាមឯកសារ Timor-Leste National Accounts 2004-2023 វិស័យឧស្សាហកម្មរបស់ទីម័រខាងកើតដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជាពិសេសក្នុងការជំរុញកំណើនសេដ្ឋកិច្ចមិនមែនប្រេង (Non-Oil GDP)។ របាយការណ៍នេះបានបែងចែកវិស័យឧស្សាហកម្មជាផ្នែកសំខាន់ៗដូចជា ឧស្សាហកម្មផលិតកម្ម សំណង់ និងការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន និងទឹក។ ផ្នែកនីមួយៗបានបង្ហាញពីការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។

ក្នុងចំណោមផ្នែកទាំងអស់នៃវិស័យឧស្សាហកម្ម វិស័យសំណង់គឺជាក្បាលម៉ាស៊ីនដ៏សំខាន់មួយក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសទីម័រខាងកើត។ យោងតាមរបាយការណ៍ Timor-Leste National Accounts 2004-2023 វិស័យនេះបានបង្ហាញពីការកើនឡើងនូវតម្លៃបន្ថែមសរុប (Gross Value Added) ស្ទើរតែរៀងរាល់ឆ្នាំ។ កំណើននេះត្រូវបានជំរុញដោយកត្តាចម្បងៗដូចជា ការវិនិយោគសាធារណៈរបស់រដ្ឋាភិបាលទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ រួមមានការសាងសង់ផ្លូវថ្នល់ ស្ពាន និងអគាររដ្ឋបាលថ្មីៗ។ ទន្ទឹមនឹងនេះ ការវិនិយោគឯកជនលើការសាងសង់អគារពាណិជ្ជកម្ម និងលំនៅឋាន ក៏ដូចជាជំនួយអន្តរជាតិលើគម្រោងសាងសង់មួយចំនួន ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍វិស័យនេះផងដែរ។ ជាក់ស្តែង របាយការណ៍នេះ បានបង្ហាញថាតម្លៃបន្ថែមសរុបនៃវិស័យសំណង់បានកើនពី ២៦១.២៧ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១ ទៅ ២៨៥.៥៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២៣។ តួលេខនេះបានបញ្ជាក់យ៉ាងច្បាស់ពីតួនាទីដ៏សំខាន់នៃវិស័យសំណង់ក្នុងការបង្កើតការងារ និងការជំរុញសេដ្ឋកិច្ចក្នុងស្រុក។

វិស័យឧស្សាហកម្មផលិតកម្ម ក៏ជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ទីម័រខាងកើត។ របាយការណ៍ដដែលនេះ បានបែងចែកវិស័យនេះជាពីរផ្នែកគឺ ឧស្សាហកម្មខ្នាតតូច ដែលភាគច្រើនផ្តោតលើការផលិតទំនិញប្រើប្រាស់ប្រចាំថ្ងៃសម្រាប់ទីផ្សារក្នុងស្រុក និងឧស្សាហកម្មផ្សេងៗទៀត។ ទោះបីជាទំហំនៃវិស័យនេះនៅមានកម្រិតទាបបើប្រៀបធៀបនឹងបណ្តាប្រទេសក្នុងតំបន់ក៏ដោយ ក៏វាបានបង្ហាញពីសក្តានុពលនៃការរីកចម្រើន។ ទិន្នន័យបង្ហាញថា តម្លៃបន្ថែមសរុបនៃឧស្សាហកម្មផលិតកម្មបានកើនពី ៣៥.១៩ លានដុល្លារ ក្នុងឆ្នាំ២០២១ ដល់ ៣៨.៤៥ លានដុល្លារ ក្នុងឆ្នាំ ២០២៣។ ការកើនឡើងនេះបង្ហាញពីសញ្ញាវិជ្ជមានមួយដែលថាសកម្មភាពផលិតកម្មក្នុងស្រុកកំពុងមានការរីកចម្រើនជាបណ្តើរៗ ដែលជាកត្តាជំរុញដល់ការកាត់បន្ថយការពឹងផ្អែកលើការនាំចូល។

ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន និងទឹក ក៏ត្រូវបានចាត់បញ្ចូលក្នុងក្រុមឧស្សាហកម្មផងដែរ។ វិស័យនេះដើរតួនាទីជាប្រព័ន្ធគាំទ្រដល់សកម្មភាពសេដ្ឋកិច្ចទាំងអស់។ ការផ្គត់ផ្គង់នៃអគ្គិសនី និងទឹកស្អាត បានគ្រប់គ្រាន់ និងមានតម្លៃថោក គឺជាកត្តាចាំបាច់សម្រាប់ការជំរុញវិស័យនានាដូចជា ឧស្សាហកម្មផលិតកម្ម កសិកម្ម និងសេវាកម្មនៅក្នុងប្រទេសទីម័រខាងកើត។ របាយការណ៍បានបង្ហាញថា តម្លៃបន្ថែមសរុបនៃវិស័យនេះបានកើនពី ១៣.២២ លានដុល្លារ ក្នុងឆ្នាំ២០២១ ដល់ ១៥.២៦ លានដុល្លារ ក្នុងឆ្នាំ ២០២៣។ កំណើននេះឆ្លុះបញ្ចាំងពីការវិនិយោគលើស្ថានីយ៍ផលិតអគ្គិសនីថ្មីៗ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ដែលកើនឡើង។

យោងតាមរបាយការណ៍របស់អង្គការ La'o Hamutuk ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅទីម័រខាងកើត ឧស្សាហកម្មប្រេងកាតនិងឧស្ម័នធម្មជាតិ គឺជាវិស័យសំខាន់បំផុតសម្រាប់សេដ្ឋកិច្ចរបស់ប្រទេស។

វិស័យនេះមិនត្រឹមតែជាប្រភពចំណូលដ៏ធំបំផុតរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងជាឆ្អឹងខ្នងដែលទ្រទ្រង់ដល់ការអភិវឌ្ឍប្រទេសទាំងមូលផងដែរ។ ធនធានប្រេងកាតនិងឧស្ម័នធម្មជាតិភាគច្រើនរបស់ទីម័រខាងកើត គឺស្ថិតនៅក្រោមសមុទ្រទីម័រ។ ប្លុកប្រេងសំខាន់ៗដែលត្រូវបានរកឃើញរួមមាន ប្លុកប្រេង Bayu-Undan និងប្លុកប្រេង Greater Sunrise។ តែមកដល់ឆ្នាំ២០២៥នេះ ប្លុកប្រេង Bayu-Undan បានរីងស្ងួត និងបញ្ឈប់ដំណើរការបូមយកប្រេងទាំងស្រុង។ ចំណូលដែលបានមកពីឧស្សាហកម្មប្រេងកាតនិងឧស្ម័នធម្មជាតិទាំងអស់ត្រូវបានបង្វែរចូលទៅក្នុង មូលនិធិប្រេងកាត( Petroleum Fund ) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៥។ មូលនិធិនេះត្រូវបានគ្រប់គ្រងដោយធនាគារកណ្តាលទីម័រខាងកើត ក្នុងគោលបំណងធានាថាធនធាននេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនទីម័រខាងកើតទាំងបច្ចុប្បន្ននិងអនាគត។ នៅដំណាច់ឆមាសទី១ ក្នុងឆ្នាំ ២០២៥ មូលនិធិប្រេងកាតនេះមានតម្លៃប្រមាណ ១៨.៧៥ ពាន់លានដុល្លារអាមេរិក។ ផលិតផលសំខាន់ដែលទីម័រខាងកើតនាំចេញគឺ ប្រេងឆៅ ឧស្ម័នធម្មជាតិរាវ ( LNG) និងឧស្ម័ន condensate ។ ការនាំចេញទាំងនេះភាគច្រើនត្រូវបានធ្វើឡើងតាមរយៈបំពង់បង្ហូរឧស្ម័ន និងនាវាដឹកជញ្ជូន។ ប្រទេសដែលទទួលទិញសំខាន់ៗរួមមាន អូស្ត្រាលី និងជប៉ុន។ ការនាំចេញទាំងនេះស្ទើរតែ ១០០% ជាចំណូលដែលនាំចូលមកក្នុងមូលនិធិប្រេងកាត។ សេដ្ឋកិច្ចរបស់ទីម័រខាងកើតពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់ចំណូលពីឧស្សាហកម្មប្រេង ដែលធ្វើឱ្យងាយរងគ្រោះដោយសារតែការប្រែប្រួលតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិ។ លើសពីនេះ បញ្ហាទាក់ទងនឹងតម្លាភាព អំពើពុករលួយ និងការគ្រប់គ្រងមូលនិធិប្រេងកាតនៅតែជាកង្វល់ដ៏ធំ។ ការទាញយកប្រេងនិងឧស្ម័នក៏អាចបង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានសមុទ្រ និងប្រព័ន្ធអេកូឡូស៊ីផងដែរ។

របាយការណ៍ Timor-Leste National Accounts 2004-2023 បានផ្តល់នូវទិន្នន័យមូលដ្ឋានដ៏រឹងមាំមួយដែលបង្ហាញថា វិស័យឧស្សាហកម្មរបស់ទីម័រខាងកើតកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសនៅក្នុងវិស័យសំណង់និងផលិតកម្ម។ កំណើនជាលំដាប់នៃវិស័យទាំងនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការកើនឡើងនៃ Non-Oil GDP ដែលបានកើនពី ១,៤ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០២១ ដល់ ១,៨ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០២៣។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីសម្រេចបាននូវកំណើនរយៈពេលវែងនិងចីរភាព ទីម័រខាងកើតចាំបាច់ត្រូវតែបន្តទាក់ទាញការវិនិយោគឯកជន បង្កើនការគាំទ្រដល់ឧស្សាហកម្មខ្នាតតូច និងមធ្យម ( SMEs ) និងអភិវឌ្ឍធនធានមនុស្សដើម្បីបង្កើនផលិតភាព។ នេះជាកត្តាចាំបាច់សម្រាប់កសាងសេដ្ឋកិច្ចមួយដែលរឹងមាំនិងមិនពឹងផ្អែកតែលើប្រាក់ចំណូលពីធនធានធម្មជាតិ។

### ៥.៤- វិស័យទេសចរណ៍

ទីម័រខាងកើត ដែលជាប្រទេសវ័យក្មេង កំពុងចាប់ផ្តើមដាក់ខ្លួនឱ្យជាគោលដៅទេសចរណ៍ដ៏លេចធ្លោមួយក្នុងតំបន់។ ជាមួយនឹងឆ្នេរខ្សាច់ដ៏ស្រស់ស្អាត បេតិកភណ្ឌវប្បធម៌ វប្បធម៌ សិល្បៈដ៏សម្បូរបែប និងសក្តានុពលទេសចរណ៍ធម្មជាតិដែលមិនទាន់ត្រូវបានទាញយក។ ប្រទេសនេះបានក្លាយជាគោលដៅដ៏គួរឱ្យទាក់ទាញសម្រាប់វិនិយោគិនដែលកំពុងស្វែងរកឱកាសវិនិយោគនៅក្នុងវិស័យទេសចរណ៍។ ទោះបីជាស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ក៏ដោយ រដ្ឋាភិបាលទីម័រខាងកើតកំពុងខិតខំយ៉ាងសកម្មដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងទាក់ទាញការវិនិយោគពីបរទេស ដែលធ្វើឱ្យពេលនេះក្លាយជាពេលវេលាដ៏សមស្របដើម្បីស្វែងរកទស្សនវិស័យអាជីវកម្មក្នុងវិស័យនេះ។ ទោះជាយ៉ាងណា វិស័យទេសចរណ៍នៅទីម័រខាងកើតនៅតែមិនទាន់ត្រូវបានគេស្គាល់ទូលំទូលាយបើប្រៀបធៀបទៅនឹងគោលដៅផ្សេងទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសនេះបាន

ឃើញការកើនឡើងគួរឱ្យកត់សម្គាល់នៃភ្ញៀវទេសចរនៅឆ្នាំ ២០២៤ ដោយមានភ្ញៀវទេសចរអន្តរជាតិប្រមាណ ៨០.០០០ នាក់ បានមកទស្សនា ដែលតំណាងឱ្យកំណើន ៥% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣។ ភ្ញៀវទេសចរភាគច្រើនបានមកពីប្រទេសអូស្ត្រាលី(៣០%) ឥណ្ឌូនេស៊ី(២៥%) ព័រទុយហ្គាល់(១៥%) និងចិន (១០%)។ ការចំណាយជាមធ្យមក្នុងម្នាក់ៗនៅឆ្នាំ ២០២៤ គឺប្រហែល ១២០ ដុល្លារអាមេរិកក្នុងមួយថ្ងៃ ដែលស្មើនឹងប្រមាណ ៨៤០ ដុល្លារអាមេរិកក្នុងមួយដំណើរទេស្សនកិច្ចជាមធ្យម។ របាយការណ៍ជាច្រើនបង្ហាញពីកំណើនចំណូលពីវិស័យទេសចរណ៍ពីប្រហែល ៦៧ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៧ ដល់ ៧៨ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៨។ បច្ចុប្បន្ន មិនទាន់មានរបាយការណ៍ផ្លូវការថ្មីៗដែលចេញផ្សាយពីចំណូលសរុបនៃវិស័យទេសចរណ៍នៅប្រទេសទីម័រខាងកើតនោះទេ។ ទិន្នន័យចុងក្រោយបំផុតដែលត្រូវបានគេប្រើប្រាស់ជាទូទៅ គឺទិន្នន័យពីឆ្នាំ ២០១៩ ដែលជាឆ្នាំចុងក្រោយមុនវិបត្តិកូវីដ-១៩។ នៅឆ្នាំ ២០១៩ ប្រទេសទីម័រខាងកើតបានទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧៥,០០០ នាក់ និងទទួលបានចំណូលសរុបប្រហែល ៧០-៧៥ លានដុល្លារអាមេរិក។ របាយការណ៍សេដ្ឋកិច្ចបច្ចុប្បន្នភាគច្រើនបង្ហាញថា វិស័យទេសចរណ៍កំពុងមានសញ្ញានៃការងើបឡើងវិញជាបណ្ដើរៗកាន់តែប្រសើរ។ ដើម្បីឆ្លុះបញ្ចាំងពីសក្ដានុពលនេះ រដ្ឋាភិបាលទីម័រខាងកើតបានកំណត់គោលដៅសម្រាប់ឆ្នាំ ២០៣០ ថានឹងទទួលស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិចំនួន ២០០.០០០ នាក់ ក្នុងមួយឆ្នាំ រកចំណូលបានប្រមាណ ១៥០ លានដុល្លារអាមេរិក និងបង្កើតការងារដោយផ្ទាល់ដល់ទៅ ១៥.០០០ កន្លែង។ កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយជំងឺរាតត្បាតបានសង្កត់ធ្ងន់ពីតម្រូវការក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដើម្បីគាំទ្រតម្រូវការដែលកំពុងកើនឡើងនេះ។ ក្រុមគោលដៅទេសចរណ៍រួមមានភ្ញៀវទេសចរដែលគិតគូរពីបរិស្ថាន ភ្ញៀវមុជទឹក ភ្ញៀវទេសចរវប្បធម៌ និងភ្ញៀវទេសចរលំដាប់ខ្ពស់ដែលស្វែងរកកន្លែងកម្សាន្តលំហែប្រណីតៗ។

វិស័យទេសចរណ៍របស់ទីម័រខាងកើតកំពុងត្រូវបានអភិវឌ្ឍដោយផ្ដោតលើការវិនិយោគលើសណ្ឋាគារឆ្នេរសមុទ្រ និងទេសចរណ៍ធម្មជាតិ(eco-tourism) ដូចជា កោះអាតៅរ៉ូ(Atauro) ដែលមានធនធានធម្មជាតិ និងជីវៈចម្រុះខ្ពស់។ តំបន់ភូមិសាស្ត្រមួយចំនួននៅទីម័រខាងកើតលេចធ្លោសម្រាប់សក្ដានុពលទេសចរណ៍របស់ពួកគេ រួមមាន ទីក្រុងឌីលី(ដែលជាច្រកចូលសំខាន់) កោះអាតៅរ៉ូ(Atauro) (ល្បីល្បាញសម្រាប់ជីវចម្រុះសមុទ្រ) ឆ្នេរភាគខាងកើត និងតំបន់ភ្នំ(សម្រាប់ទេសចរណ៍ផ្សងព្រេង)។



***ភ្នំ និង ឆ្នេរសមុទ្រ នៃប្រទេសទីម័រខាងកើត***

រដ្ឋាភិបាលទីម័រខាងកើតកំពុងលើកទឹកចិត្តយ៉ាងសកម្មដល់ការវិនិយោគក្នុងវិស័យទេសចរណ៍ តាមរយៈគោលនយោបាយ និងការលើកទឹកចិត្តជាច្រើន រួមមាន ការលើកលែងពន្ធរហូតដល់ ១០ ឆ្នាំ សម្រាប់គម្រោងវិនិយោគ ដំណើរការទិញដីងាយស្រួល ការលើកលែងពន្ធគយលើសម្ភារៈវិនិយោគ និង កិច្ចព្រមព្រៀងស្ថិរភាពផ្លូវច្បាប់។ ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលក៏បានវិនិយោគយ៉ាងសកម្មលើហេដ្ឋារចនាសម្ព័ន្ធ ដោយបានរៀបចំវេទិកាវិនិយោគទេសចរណ៍លើកទីមួយនៅឆ្នាំ ២០២៤ និងដាក់ឱ្យដំណើរការ ផែនការមេដឹកជញ្ជូនសាធារណៈរបស់ទីម័រខាងកើត( TLPTMP ) ដើម្បីពង្រឹងការតភ្ជាប់ជាមួយនឹងជើងហោះហើរប្រចាំសប្តាហ៍ចំនួន ៣០ ជើងទៅនិងមកពីទីក្រុងឌីលី។

### ៥.៥- វិស័យគមនាគមន៍

វិស័យគមនាគមន៍នៅប្រទេសទីម័រខាងកើត កំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍យ៉ាងសកម្ម ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ច និងតម្រូវការសង្គម។ វិស័យនេះត្រូវបានចាត់ទុកជាកម្លាំងចលករដ៏សំខាន់មួយក្នុងការតភ្ជាប់តំបន់ផ្សេងៗនៃប្រទេស ក៏ដូចជាការតភ្ជាប់ទៅកាន់ពិភពលោក។ ការដឹកជញ្ជូនតាមផ្លូវគោក គឺជាមធ្យោបាយដ៏សំខាន់បំផុតសម្រាប់ប្រជាជនភាគច្រើន។ ប្រព័ន្ធផ្លូវគោកសរុបមានប្រវែងប្រហែល ៦.២០០ គីឡូម៉ែត្រ ដែលរួមមានផ្លូវជាតិ(ប្រហែល ១.៤៣៥ គីឡូម៉ែត្រ) ផ្លូវស្រុក និងផ្លូវជនបទ។ ទោះបីជាផ្លូវសំខាន់ៗត្រូវបានកែលម្អដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍អន្តរជាតិដូចជា ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី ក៏ដោយ ក៏ផ្លូវនៅតំបន់ដាច់ស្រយាលនៅតែជាបញ្ហាប្រឈម ជាពិសេសក្នុងរដូវវស្សា។ រដ្ឋាភិបាលកំពុងផ្តោតលើការកសាងផ្លូវដែលធន់នឹងអាកាសធាតុដើម្បីដោះស្រាយបញ្ហានេះ។ ការតភ្ជាប់តាមផ្លូវអាកាស មានសារៈសំខាន់សម្រាប់ការទេសចរណ៍ និងពាណិជ្ជកម្ម។ ព្រលានយន្តហោះអន្តរជាតិប្រេស៊ីដិន នីកូឡៅ ឡូបាតូ( Presidente Nicolau Lobato ) នៅទីក្រុងឌីលី ជាច្រកទ្វារអន្តរជាតិដែលបានតភ្ជាប់ទីម័រខាងកើតទៅនឹងពិភពលោកខាងក្រៅ ជាពិសេសជើងហោះហើរត្រង់ទៅប្រទេសក្នុងតំបន់មួយចំនួនដូចជា ឥណ្ឌូណេស៊ី សិង្ហបុរី ម៉ាឡេស៊ី អូស្ត្រាលី និងចិន តាមរយៈក្រុមហ៊ុនអាកាសចរណ៍ដូចជាអ៊ែរ៉ូ ឌីលី( Aero Dili ), ស៊ីធីលីង( Citilink ), បាទីក អ៊ែរ( Batik Air ), អ៊ែរណេត( Airnorth ) និងខ្វាន់តាស( Qantas )។ ម៉្យាងទៀត ការតភ្ជាប់តាមផ្លូវសមុទ្រ កំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ កំពង់ផែទឹកជ្រៅទីបារបេ( Tibar Bay ) ថ្មីដែលស្ថិតនៅជិតក្រុងឌីលី ត្រូវបានសាងសង់ក្រោមភាពជាដៃគូសាធារណៈ-ឯកជន ( PPP ) ដើម្បីជំនួសកំពង់ផែចាស់ និងបង្កើនសមត្ថភាពទទួលកុងតឺន័របានច្រើនជាងមុន ដើម្បីគាំទ្រដល់ពាណិជ្ជកម្មអន្តរជាតិ។

### ៥.៦- វិស័យពាណិជ្ជកម្ម

វិស័យពាណិជ្ជកម្មរបស់ប្រទេសទីម័រខាងកើតគឺ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការនាំចេញប្រេងកាតនិងឧស្ម័នធម្មជាតិ ហើយត្រូវប្រឈមមុខនឹងឱនភាពពាណិជ្ជកម្មដ៏ធំ។ យ៉ាងណាមិញ ប្រទេសនេះកំពុងធ្វើការយ៉ាងសកម្មដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។

សេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ប្រទេសទីម័រខាងកើតគឺពឹងផ្អែកយ៉ាងខ្លាំងលើចំណូលពីប្រេងកាត និងឧស្ម័នធម្មជាតិនៅតំបន់សមុទ្រ។ ប្រេងកាត និងឧស្ម័នធម្មជាតិ គឺជាទំនិញនាំចេញដ៏សំខាន់បំផុតរបស់ប្រទេស

នេះ ដោយមានចំណែកយ៉ាងធំនៅក្នុងតម្លៃនៃការនាំចេញសរុប។ ការពឹងផ្អែកនេះធ្វើឱ្យសេដ្ឋកិច្ចងាយរងគ្រោះនឹងការប្រែប្រួលតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ។ ក្រៅពីនេះ ប្រទេសនេះតែងតែមានឱនភាពពាណិជ្ជកម្មទំនិញដ៏ធំ ដោយសារតែការនាំចូលទំនិញ និងសេវាកម្មជាច្រើនប្រភេទដូចជា ប្រេងចម្រាញ់ អាហារ និងសម្ភារៈសំណង់ ខណៈដែលសមត្ថភាពនាំចេញទំនិញមិនមែនប្រេងមានកម្រិតទាបខ្លាំង។ ទោះជាយ៉ាងនេះក្ដី ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការត្រៀមខ្លួនក្លាយជាសមាជិកពេញសិទ្ធិរបស់សមាគមអាស៊ាន គឺជាជំហានយុទ្ធសាស្ត្រដើម្បីទាក់ទាញការវិនិយោគបរទេស និងជំរុញកំណើនពាណិជ្ជកម្ម។ ក្រៅពីប្រេងកាត និងឧស្ម័នធម្មជាតិ ដែលជាទំនិញនាំចេញចម្បង ទីម័រខាងកើតក៏មានការនាំចេញផលិតផលកសិកម្មសំខាន់ៗមួយចំនួនផងដែរដូចជា កាហ្វេ ដែលល្បីល្បាញដោយសារគុណភាពល្អ និងវ៉ានីឡាជាដើម។ ចំណែកឯទំនិញនាំចូលវិញមានភាពចម្រុះ រួមមាន ប្រេងចម្រាញ់ យានយន្ត គ្រឿងម៉ាស៊ីន សម្ភារៈសំណង់ អាហារ និងភេសជ្ជៈជាដើម។ ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ខ្លួនសម្រាប់ទាំងការនាំចេញ និងនាំចូលរួមមានប្រទេសចិន ឥណ្ឌូនេស៊ី សិង្ហបុរី កូរ៉េខាងត្បូង ជប៉ុន និងអូស្ត្រាលី។

របាយការណ៍ស្ថិតិពាណិជ្ជកម្មផ្លូវការរបស់វិទ្យាស្ថានជាតិស្ថិតិនៃប្រទេសទីម័រខាងកើត (Institut Nacional de Estatística de Timor-Leste - INETL) ដែលបានបោះពុម្ពផ្សាយនៅខែកក្កដា ឆ្នាំ២០២៤ បង្ហាញពីទិន្នន័យនាំចូលនិងនាំចេញទំនិញ និងសេវាកម្ម ប្រមាណរយៈពេលមួយឆ្នាំ ២០២៣។ ក្នុងរបាយការណ៍នេះបានបង្ហាញពីការនាំចូលទំនិញបានកើនឡើងដល់ ៨៣៧.៥ លានដុល្លារ ក្នុងឆ្នាំ ២០២៣ ដែលជាការកើនឡើងបន្តិចបន្តួចពី ៨២០.២ លានដុល្លារ ក្នុងឆ្នាំ ២០២២។ ការនាំចូលមិនមែនទំនិញ(សេវាកម្ម ឬប្រតិបត្តិការដែលមិនមែនទំនិញ) បានធ្លាក់ចុះនៅត្រឹម ៧២.៣ លានដុល្លារ ក្នុងឆ្នាំ២០២៣ ដែលជាការធ្លាក់ចុះខ្លាំងពី ១១៣.២ លានដុល្លារ ក្នុងឆ្នាំ២០២២។ ការនាំចូលសរុបបានធ្លាក់ចុះនៅត្រឹម ៩០៩.៨ លានដុល្លារ ក្នុងឆ្នាំ២០២៣ ដែលជាការធ្លាក់ចុះច្រើនពី ៩៣៣.៤ លានដុល្លារ ក្នុងឆ្នាំ២០២២។ ការកើនឡើងនៃការនាំចូលទំនិញក្នុងឆ្នាំ២០២៣នេះ ត្រូវបានជំរុញជាចម្បងដោយការកើនឡើងយ៉ាងខ្លាំងនូវ ទំនិញវិនិយោគ(វត្ថុ ឬឧបករណ៍ធំៗដែលប្រើប្រាស់សម្រាប់ផលិតទំនិញ ឬផ្ដល់សេវាកម្មផ្សេងទៀត)(កើនឡើង ២២%) ទំនិញជាវត្ថុធាតុដើម ឬទំនិញពាក់កណ្ដាលសម្រេច(កើនឡើង ១៨%) និង ទំនិញសម្រាប់ប្រើប្រាស់ឬផលិតផលសម្រេច (កើនឡើង ១២%)។ ក្នុងចំណោមទំនិញនាំចូលកំពូលទាំងដប់ ប្រេងឥន្ធនៈ និងផលិតផលសម្រេចពីប្រេងកាត គឺជាមុខទំនិញនាំចូលធំជាងគេ ដោយមានតម្លៃរហូតដល់ ១៨៦.៣ លានដុល្លារ។ បន្ទាប់មកគឺយានយន្ត (៩២.៩ លានដុល្លារ) ធញ្ញជាតិ(៧៧.៨ លានដុល្លារ) គ្រឿងចក្រ និងឧបករណ៍អគ្គិសនី(៤៥.៦ លានដុល្លារ) រ៉េអាក់ទ័រនុយក្លេអ៊ែរ ឡចំហាយ និងគ្រឿងចក្រ (៤១.៣ លានដុល្លារ) ផលិតពីធញ្ញជាតិ និងម្សៅ(២៨.២ លានដុល្លារ) សាច់ និងសរីរាង្គសត្វសម្រាប់បរិភោគ (២៧.៩ លានដុល្លារ) ដែក និងដែកថែប(២៨.៨ លានដុល្លារ) ស៊ីម៉ងត៍(២៦.៤ លានដុល្លារ) និងគ្រឿងសង្ហារិម ពូក(១៨.៩ លានដុល្លារ)។ ប្រទេសឥណ្ឌូនេស៊ី នៅតែជាដៃគូពាណិជ្ជកម្មនាំចូលធំជាងគេរបស់ទីម័រខាងកើត ដែលមានតម្លៃដល់ទៅ ២៩៧.៨ លានដុល្លារ។ បន្ទាប់មក ចិន(១២៨.៦៣លានដុល្លារ) សិង្ហបុរី (៩៤.២៤លានដុល្លារ) អូស្ត្រាលី(៦០.៤៧លានដុល្លារ) និងឥណ្ឌា(៥២.១៥លានដុល្លារ)។

ផ្ទុយទៅវិញ ការនាំចេញក្នុងស្រុកបានធ្លាក់ចុះយ៉ាងខ្លាំងមកត្រឹម ១២៧.៨ លានដុល្លារ ក្នុងឆ្នាំ ២០២៣ ធៀបនឹង ៣៥១.២ លានដុល្លារ ក្នុងឆ្នាំ ២០២២។ ការនាំចេញឡើងវិញបានកើនឡើងដល់ ៣៥.៩ លានដុល្លារ

ក្នុងឆ្នាំ២០២៣ ធៀបនឹង ២១.៣ លានដុល្លារ ក្នុងឆ្នាំ២០២២។ ការនាំចេញសរុបទាំងអស់(ការនាំចេញក្នុងស្រុក និងការនាំចេញឡើងវិញ) មានចំនួន ១៦៣.៧ លានដុល្លារ មានការធ្លាក់យ៉ាងគំហុក បើធៀបក្នុងឆ្នាំ ២០២២ ដែលមាន ៣៧២.៥ លានដុល្លារ។ ការធ្លាក់ចុះយ៉ាងគំហុកនេះ គឺបណ្ដាលមកពីការថយចុះយ៉ាងខ្លាំងនៃការនាំចេញប្រេងកាត និងឧស្ម័នធម្មជាតិ ដែលធ្លាក់ចុះពី ៣២១.៨ លានដុល្លារ ក្នុងឆ្នាំ ២០២២ មកនៅត្រឹម ១១០.៣ លានដុល្លារ ក្នុងឆ្នាំ ២០២៣ ដោយសារផលិតកម្មថយចុះ។ បន្ថែមពីលើនេះ ការនាំចេញ កាហ្វេ ក៏បានធ្លាក់ចុះផងដែរ ដោយពីតម្លៃ ២៦.១ លានដុល្លារ ក្នុងឆ្នាំ ២០២២ មកនៅត្រឹម ១៤.៥ លានដុល្លារ ក្នុងឆ្នាំ ២០២៣។ ទោះបីជាការនាំចេញសរុបមានការធ្លាក់ចុះយ៉ាងណាក៏ដោយ ប្រទេសចិន បានក្លាយជាដៃគូពាណិជ្ជកម្មនាំចេញធំជាងគេរបស់ទីម័រខាងកើត ដែលមានតម្លៃ ៧៦.១ លានដុល្លារ បន្ទាប់មកមាន សិង្ហបុរី (៣១.២៤ លានដុល្លារ) អូស្ត្រាលី(២៧.៥៦លានដុល្លារ) ឥណ្ឌូនេស៊ី(១១.៧៦លានដុល្លារ) និង ជប៉ុន (៤.៨៤លានដុល្លារ)។

យោងតាមទិន្នន័យនេះ ស្ថានភាពពាណិជ្ជកម្មរបស់ប្រទេសទីម័រខាងកើតក្នុងឆ្នាំ ២០២៣ អាចបង្ហាញជាតួលេខច្បាស់លាស់។ ទំហំនាំចូលសរុបមានប្រមាណ ៩០៩.៨ លានដុល្លារអាម៉េរិក (រួមបញ្ចូលទាំងទំនិញ និងមិនមែនទំនិញ) ខណៈដែលទំហំនាំចេញសរុប(ផលិតក្នុងស្រុក និងទំនិញនាំចេញឡើងវិញ)មានត្រឹមប្រមាណ ១៦៣.៧ លានដុល្លារអាម៉េរិក តែប៉ុណ្ណោះ។ ដូច្នេះ ទំហំពាណិជ្ជកម្មសរុបរបស់ប្រទេសនេះមានប្រមាណ ១,០៧៣.៥ លានដុល្លារអាម៉េរិក។ ទិន្នន័យនេះបានបង្ហាញយ៉ាងច្បាស់ថា ប្រទេសទីម័រខាងកើតមានឱនភាពពាណិជ្ជកម្ម ដ៏ធំធេងរហូតដល់ប្រមាណ ៧៤៦.១ លានដុល្លារអាម៉េរិក។ នេះឆ្លុះបញ្ចាំងពីការពឹងផ្អែកខ្ពស់លើការនាំចូល ដើម្បីបំពេញតម្រូវការក្នុងស្រុក ដែលជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់សេដ្ឋកិច្ចរបស់ប្រទេស។

# ឯកសារយោង


1. ក្រសួងអប់រំ យុវជន និងកីឡា(២០២០). *សិក្សាសង្គមថ្នាក់ទី៨.* គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ. ភ្នំពេញ. ទំព័រ៤២-៤៧.
2. BirdLife International. (2021). *Bird Species in Timor-Leste*. BirdLife International. https://www.birdlife.org/country/timor-leste/
3. Central Intelligence Agency. (n.d.). *Timor-Leste—The World Factbook*. https://www.cia.gov/the-world-factbook/countries/timor-leste/
4. Central Intelligence Agency. (n.d.). *Timor-Leste—The World Factbook*. (2023 ed.). https://www.cia.gov/the-world-factbook/about/archives/2023/countries/timor-leste/
5. Falak, A. (2025, February 19). *Investment opportunities in Timor-Leste's tourism industry*. ASEAN Business News. https://www.aseanbriefing.com/news/investment-opportunities-in-timor-lestes-tourism-industry/
6. Government of Timor-Leste. (n.d.). *Administrative Division*. https://timor-leste.gov.tl/?p=91&lang=en
7. Government of Timor-Leste. (n.d.). *Government reaffirms confidence in the judicial institutions and the new president of the Court of Appeal*. https://timor-leste.gov.tl/?p=43222&lang=en
8. Government of Timor-Leste. (n.d.). *Political system*. https://timor-leste.gov.tl/?p=33&lang=en
9. Mendes, H. H., & Institute National Statistics of Timor-Leste (INETL). (2023). *EXTERNAL TRADE STATISTICS 2023* (E. M. Ximenes, L. D. J. Moreira, & A. D. F. Soares, Eds.). https://www.laohamutuk.org/DVD/DGS/Anual-Trade-2023.pdf
10. Ministry of Finance of Timor-Leste, National Institute of Statistics, Ferreira, E. D. S., & De Sousa, F. B. (2024). *Timor-Leste's national accounts 2004-2023*. https://www.laohamutuk.org/DVD/DGS/NatlAccts2023en.pdf
11. Ministry of Tourism. (2025, May 19). *Timor Leste Culture and its People | Tourism Timor Leste*. Tourism Timor-Leste. https://www.timorleste.tl/east-timor/about/people-culture/
12. Oilwatch. (n.d.). *Oil in Timor-Leste*. La'o Hamutuk. https://www.laohamutuk.org/Oil/curse/OilInTLOilwatch.htm
13. Statista. (2025, July 3). *Share of economic sectors in the GDP in Timor-Leste 2023*. https://www.statista.com/statistics/728875/share-of-economic-sectors-in-the-gdp-in-timor-leste/
14. SBS. (2022). *East Timorese - Religion*. Cultural Atlas. https://culturalatlas.sbs.com.au/east-timorese-culture/east-timorese-culture-religion
15. Timor-Leste National Institute of Statistics. (2023). *Timor-Leste Population and Housing Census 2022 main report*. UNFPA Timor-Leste. https://timor-leste.unfpa.org/sites/default/files/pub-pdf/final-main-report_tlphc-census_2022.pdf
16. TradeInvest Timor-Leste. (2022, January 5). *AGRICULTURE SECTOR*. https://www.tradeinvest.tl/node/22


Chhorn Ratana, 2025